# កិច្ចសំភាសន៏ទាក់ទងនឹងការគប់គ្រាប់បែកដៃ
# នៅមុខរដ្ឋសភាជាតិ
# នាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៧

*លោក អេង ឆៃអ៊ាង និងលោកស្រី ជូឡុង សូមូរ៉ា ជាមួយនិង*
*លោក ឆាយវី និង លោក ជុំ ប៊ុនធឿន*

អ៊ាង : ឆាយវីឯងស្គាល់លោក ហ៊ីង ប៊ុនហៀងពេលណា?

ឆាយវី : ស្គាល់ ! អារ៉ែង មួយភ្លែត ! ខ្ញុំជួប កាលជួបហ្នឹងមិនប្រាប់ខ្ញុំថា បញ្ហាអ្វីមួយហ្នឹងខ្ញុំមិនទាន់ ដឹងថារឿងអីៗទេ ប៉ុន្តែជួបនៅពេលដែល លោកហ្នឹងឯង លោកហ្នឹង ហ៊ីង ប៊ុនហៀងក៏មិនដឹង ឬលោកណាក៏មិនដឹងដែរ ខ្ញុំមិនទាន់ស្គាល់គេ

អ៊ាង : ពេលនោះអ្នកណាអ្នកនាំធឿនឯងមកជួបនឹងហ៊ីង ប៊ុនហៀង?

ឆាយវី : ខ្ញុំទៅជាមួយលោកនេះ

អ៊ាង : ប៉ុន្មានថ្ងៃ មុនថ្ងៃបោកគ្រាប់បែក?

ឆាយវី : កាលពីថ្ងៃ ២៦

អ៊ាង : អញ្ចឹង ! នៅពេលជួបនោះអត់ដឹងថា ហ៊ីង ប៊ុនហៀង ទេ

ឆាយវី : អត់ទេ ! អត់ដឹងទេ ! ព្រោះខ្ញុំអត់ដែលស្គាល់គាត់ផង

អ៊ាង : ចុះពេលណាដែលបានដឹងថា គាត់ហ្នឹងជា ហ៊ីង ប៊ុនហៀង?

ឆាយវី : ពេលហើយ បានគេប្រាប់ថា ហ៊ីង ប៊ុនហៀង ។ ពេលហើយ ពេលគាត់ចេញពីនោះមកវិញ មានចេញពីកន្លែងដែលខ្ញុំកំពុងនិយាយការងារហ្នឹង ក៏មិនទាន់និយាយពីរឿងការងារអ្វីមួយដែរ គ្រាន់តែទំនាក់ទំនងពីរឿងបញ្ហា ពីនេះពីនោះ ព្រោះ អានេះវាមានពីដើមឡើយហ្នឹងមានបញ្ហាការដែលទៅជាមួយនិយាយរឿងទាហ៊ានមកពីឥណ្ឌូនេស៊ី រឿងកំម្មងដូ ហើយក៏មាន ពេលគេកំពុងនិយាយអញ្ចឹងខ្ញុំក៏ទំលាក់រឿងនោះមកដោយសារ ដោយសារថ្ងៃ ១៥ ហ៊ីង ប៊ុនហៀង អត់ពាក់ព័ន្ធទេ...

អ៊ាង : ប៉ុន្តែក្រោយពីជួបគាត់ហើយ ក្រោយដឹងថា គាត់ ហ៊ីង ប៊ុនហៀងហើយ តើមានដឹងថាគាត់មានតួនាទីអ្វី មានដឹងទេ?

ឆាយវី : អត់មានដឹងតួនាទីអ្វីទេ

អ៊ាង : គ្រាន់តែដឹង ហ៊ីង ប៊ុនហៀង

ឆាយវី : ដល់គេប្រាប់ហើយ ផុតពីគេហើយ បានគេប្រាប់ថា ហ្នឹងហើយហ៊ីង ប៊ុនហៀង ប្រធានអង្គរក្ស ហ៊ុន សែន

អ៊ាង : ហើយថ្ងៃ២៦ដែលធឿនឯងទៅទួលក្រសាំងហ្នឹង អូនៃ ឆាយវីទៅទួលក្រសាំហ្នឹង ទៅលេងធម្មតា ?

ឆាយវី : ទៅលេងធម្មតា

អ៊ាង : ឬគេហៅ ?

ឆាយវី : អត់ទេ ! ទៅលេងធម្មតា លេងទៅ ឃើញគេហៅនៅហ្នឹងបណ្តោយ

អ៊ាង : បំណងទៅហ្នឹង ទៅលេងពួកម៉ាក?

ឆាយវី : ទៅលេងពួកម៉ាក ពួកម៉ាកធ្វើការនៅកន្លែងហ្នឹង

អ៊ាង : ពួកម៉ាកហ្នឹងមាននរណាខ្លះ?

ឆាយវី : អាសុន, អាហាក់ មានច្រើន ខ្ញុំភ្លេចឈ្មោះហើយច្រើន ពួកឆ័ត្រយោង

អ៊ាង : ពួកឆ័ត្រយោង ពួកហ្នឹងពេលត្រឡប់មកពីឥណ្ឌូនេស៊ីវិញ បានគេរើសចូលអង្គរក្ស គេរើសចូល ឬក៏សុំគេចូល?

ឆាយវី : អត់ទេ ! គេរើសចូល ។ ចេញពីគេមក ចេញពីគេមក បានយកពីកងពលទៅបណ្តោយ

អ៊ាង : ពេលនោះ គឺថា ពេលដែលជួប ហ៊ីង ប៊ុនហៀងហ្នឹង ថ្ងៃ២៦អត់មាននិយាយរឿងអីទេ?

ឆាយវី : អត់មាននិយាយរឿងអីទេ

អ៊ាង : ប៉ុន្តែគាត់មានសួរថាម៉េចទេ?

ឆាយវី : គាត់មានសួរខ្ញុំថាមិនស្គាល់ ហ៊ីង ប៊ុនហៀងទេ ប៉ុន្តែពេលដែលគាត់និយាយ គាត់ទំនាក់ទំនងទំលាក់ពីរឿងហ្នឹងឯង

អ៊ាង : ប៉ុន្តែគាត់សួរថាម៉េច ?

ឆាយវី : គាត់សួរថា កាលដែលរៀនប៉ុន្មានខែ ខ្ញុំថាទៅរៀនប្រាំបីខែជាង ប៉ុន្តែគេ ដូចថា គេបំប៉នជាប់ប្រាំបួនខែ ហើយដល់ពេលខ្ញុំបកមកវិញហ្នឹង ខ្ញុំក៏មានការងារធ្វើធម្មតា ប៉ុន្តែថាប្រាក់ខែវាគ្មាន អញ្ចឹងបងណា។ ហើយដល់ពេលខ្ញុំបកមកវិញនេះ ហើយក៏គាត់សិន កុំអាលទាន់និយាយរឿងហ្នឹង នៅជាមួយគាត់សិនទៅ ក្រែងលោមានប្រាក់ខែអីណាអញ្ចឹងទៅក្រែងវាធូរខ្លះ អញ្ចឹងទៅណាបងណា ហើយបើកាលណា ខ្ញុំមានប្រាក់ខែ ខ្ញុំអាចសុំគេមកនៅជាមួយបងម្តង ហើយក៏ផ្អាកប៉ុណ្ណឹងទៅ ក៏សំរាកមួយសន្ទុះ ប្រហែលកន្លះម៉ោង ក៏បានបណ្តាញម្នាក់ទៀតមកនិយាយ ខ្ញុំមិនស្គាល់គេដែរ គេក៏និយាយពីនេះពីនោះរឿងការងារហើយក៏មិនទាន់ទំលាក់ទៅលើកន្លែងនោះដែរ ។ ហើយដល់ពេលបាន...

អ៊ាង : ការងារហ្នឹងវាជាការងារធម្មតាទេ ហើយការងារបោកគ្រាប់បែកមិនទាន់និយាយទេ?

ឆាយវី : បាទ ! ការងារធម្មតាទេ

អ៊ាង : ការងារលោកគ្រាប់បែកអត់ទាន់និយាយទេ?

ឆាយវី : អត់ទាន់និយាយទេ ហើយដល់ពេលនោះទៅបានមួយសន្ទុះបានគេនិយាយ បានអានេះប្រាប់ ក៏នៅហ្នឹងដែរ នៅជាមួយគ្នាហ្នឹង ទាំងវាទាំងខ្ញុំ នៅជាមួយគ្នា ទើបនិយាយគ្នាលើឡាន ពីបញ្ហាបោកគ្រាប់បែក

អ៊ាង : និយាយលើឡាន និយាយថ្ងៃប៉ុន្មាន?

ឆាយវី : ២៦ដដែលទេ

អ៊ាង : ២៦ពេលជួបគ្នាហើយហ្នឹង ហើយបាននិយាយគ្នាក្នុងឡាន

ឆាយវី : អាពេលជួបហ្នឹងនិយាយទំនាក់ទំនងគ្នា ប៉ុន្តែ ដូចថា មិនទាន់អញ្ចេះអញ្ចុះ ហើយដល់ពេលជិះឡាន...

អ៊ាង : ជិះឡានហ្នឹងថ្ងៃ២៦ដដែល ?

ឆាយវី : ថ្ងៃ២៦ដដែលហ្នឹង មកវិញ

អ៊ាង : ជិះឡានហ្នឹងគ្នាប៉ុន្មាននាក់?

ឆាយវី : ខ្ញុំ ពីរនាក់វា គាត់

អ៊ាង : លោក ហ៊ីង ប៊ុនហៀងផ្ទាល់ ហើយឈប់ ខ្ញុំចង់សួរបន្តិច ពេលដែលជួប ហ៊ីង ប៊ុនហៀងនៅទួលក្រសាំងហ្នឹងជួបនៅម៉ោងប៉ុន្មានដែរ ពេលដែលយើងគិត ថ្ងៃត្រង់ហ្នឹង ?

ឆាយវី : អត់ទេ ! ជួបគ្នាពេលព្រឹក ប្រហែលម៉ោង១០ហ្នឹង

អ៊ាង : ពេលនោះ ឆាយវីឯងជួបគ្នាម្នាក់ៗឬ?

ឆាយវី : អត់ទេ ! ជួបទាំងអស់គ្នា

អ៊ាង : ធឿនឯងនៅហ្នឹងដែរ?

ធឿន : បាទ !

អ៊ាង : តើអត់មាននិយាយការងារអីទេ ពេលជួបគ្នាចប់ហើយបានគាត់ជូនឡានមក?

ឆាយវី : បាទ !

អ៊ាង : គាត់ជូនឡានមក គាត់សួរ គាត់សួរថាម៉េច?

ឆាយវី : គាត់សួរ គាត់ថា ឥឡូវបើមិននេះទេធ្វើការជាមួយគេទៅ ហើយខ្ញុំសួរថា ការងារអីបង? ខ្ញុំរកការងារ ការងារប្រើតិរិះអោយឯងម្នាក់មួយម៉ឺនដុល្លារចាយ បើចង់ដឹងសួរពួកម៉ាកឯងទៅ បានសួរលោកធឿននេះ បានអាធឿនគេរៀបរាប់ប្រាប់ អញ្ចឹងៗទៅហើយក៏ជិះមកជាមួយគ្នាមក ក៏អោយលុយខ្ញុំមួយពាន់ ហើយខ្ញុំចុះ...

អ៊ាង : ប៉ុន្តែមុនថ្ងៃទី២៦ មុនដែលពេលឆាយវីឯងទៅទួលក្រសាំងហ្នឹង ធឿនមាននិយាយប្រាប់ការងារអីខ្លះមុនទេ?

ឆាយវី : មានប្រាប់ខ្លះដែរ

អ៊ាង : មានប្រាប់ថាម៉េច?

ឆាយវី : ប្រាប់ថា បើមិននេះធ្វើការងារអង្គរក្សអីជាមួយគេសិនទៅណា ក្រែងលោបានលុយបានកាក់ ឥឡូវនេះ គេកំពុង រកមនុស្ស

អ៊ាង : ប៉ុន្តែ អត់ដឹងថាមានផែនការអីទេ?

ឆាយវី : អត់ដឹង ! ខ្ញុំក៏មិនដឹងថាមានអីដែរ គ្រាន់តែថា គេថា កំពុងរកមនុស្ស

អ៊ាង : ធឿន ដែលទៅជួបជាមួយ ឆាយវី មុនថ្ងៃ២៦ហ្នឹង មានជួបឆាយវីថ្ងៃប៉ុន្មានដែរ ធឿនឯងមានចាំទេ? ជុំវិញការរកការងារធ្វើ ?

ធឿន : ក្នុងថ្ងៃ២៣ បង

អ៊ាង : ចុះ លឺល្បីថា ហ៊ីង ប៊ុនហៀងទុកចិត្តធឿនឯងពេលដែលនិយាយក្នុងឡានជាមួយឆាយវី ?

ឆាយវី : បាទ ! បាទ ! ទុកចិត្ត

អ៊ាង : ឥឡូវបន្ទាប់ពីមកដល់ច្រមុះជ្រូកហើយ ចុះពីឡានហើយ ពេលនោះតើឆាយវីឯងទៅណាទៀត ?

ឆាយវី : ខ្ញុំចុះពីរថយន្តហើយ ចូលបូលឌីញ

អ៊ាង : ចូលបូលឌីញ ?

ឆាយវី : ចូលបូលឌីញទៅរកទិញម៉ូតូនៅផ្សារថ្មី

អ៊ាង : ទិញម៉ូតូអស់ប៉ុន្មាន ?

ឆាយវី : ម៉ូតូអស់ ៨០០ សល់១០០អោយបងធឿន

អ៊ាង : រួចហើយបានម៉ូតូជិះដើរលេងទៅ រួចទៅកំបូលវិញទេ ?

ឆាយវី : ទៅ ! ទៅកំបូលល្ងាចហ្នឹង

អ៊ាង : រួចហើយគេណាត់ឲ្យមកនៅពេលណាដែរ ?

ឆាយវី : គេណាត់ឲ្យមកនៅថ្ងៃ៣០ មកពីព្រឹក

អ៊ាង : ចុះថ្ងៃ២៧-២៨ គេមិនណាត់ឲ្យមកទេ ?

ឆាយវី : អត់មានមកទេ ថ្ងៃ២៧-២៨

អ៊ាង : ថ្ងៃ៣០ មកពេលព្រឹក ?

ឆាយវី : បាទ ! មកពេលព្រឹក ប្រហែលម៉ោង៨ភ្លឺ

អ៊ាង : មកទៅ គេអោយទៅជួបគេនៅឯណា ?

ឆាយវី : ជួបនៅក្រោយវត្ត

អ៊ាង : ពេលនោះ ឆាយវីឯងជិះអីទៅ ?

ឆាយវី : ខ្ញុំជិះម៉ូតូមក ខ្ញុំដាក់ម៉ូតូខ្ញុំនៅវត្តហ្នឹង ហើយរៀបចេញហ្នឹង បានជិះម៉ូតូឌុបទៅ

អ៊ាង : រៀបចេញ ?

ឆាយវី : បាទ ! ចេញទៅធ្វើបេសកកម្មគេនោះទៅណា

អ៊ាង : ឥឡូវពេលមកដល់វត្ត ពេលម៉ោង ៤ ឆាយវីឯង ពេលមកដល់ក្រោយវត្តហ្នឹងម៉ោងប៉ុន្មាន ?

ឆាយវី : ពេលមកដល់វត្តហ្នឹង ម៉ោងប្រហែល៤ ខ្ញុំអាល័យហូបចុកតិចតួច បានមកដល់ម៉ោងប្រហែល ៥

អ៊ាង : ពេលចេញពីកំបូលមក ?

ឆាយវី : ម៉ោង៤ ម៉ោង៤ទៀបភ្លឺ

អ៊ាង : ហើយបន្ទាប់មក មកដល់វត្តប្រហែលម៉ោងប៉ុន្មាន ?

ឆាយវី : មកដល់ប្រហែល ម៉ោង៤កន្លះ

អ៊ាង : ហើយមកដល់វត្តមានជួបពីណា ?

ឆាយវី : អត់មានជួបនរណា ឃើញតែមនុស្សពីរបីនាក់ ប៉ុន្តែមិនដឹងជាអ្នកណាទេ

អ៊ាង : ហើយគេស្លៀកពាក់របៀបម៉េចដែរ ?

ឆាយវី : មានស៊ីវិល មានទាហាន

អ៊ាង : មានស៊ីវិល មានទាហាន ហើយគេអត់មានសួរនាំឆាយវីឯងអីទេ ?

ឆាយវី : អត់មានទេ ខ្ញុំអង្គុយតែខ្ញុំ គេនៅតែគេ ខ្ញុំទៅណាក៏បានដែរ

អ៊ាង : ពេលធម្មតា ប្លុកហ្នឹងមិនងាយចូលងាយទេណា

ឆាយវី : បាទ !

អ៊ាង : ពេលឆាយវីឯងចូល ទំនាក់ទំនងម៉េចទើបបានចូល ?

ឆាយវី : ខ្ញុំទំនាក់ទំនង គេអោយខ្ញុំជួបគេនៅត្រង់ហ្នឹងបណ្តោយទៅខ្ញុំចូលបណ្តោយ

អ៊ាង : ព្រោះធម្មតាមានទាហាន

ឆាយវី : បាទ ! មានទាហាន ទាហានពេលទាហាននោះចូលគេអោយចូលបណ្តោយ គេអោយចូលតាមដំណើរ

អ៊ាង : អូ ! ចូលតាមដំណើរ ហើយគេអត់មានសួរនាំអីទេ ?

ឆាយវី : បាទ ! គេអត់មានសួរនាំអីទេ សួរនាំថាទៅណាអត់មានសួរទេ

អ៊ាង : គេឲ្យចូលតាមដំណើរ ចូលតាមច្រកណា ?

ឆាយវី : ចូលតាមក្រោយ មិនមែនចូលតាមនេះទេ ចូលពីក្រោយមកវិញ ចូលពីក្រោយរាំងមកវិញ

អ៊ាង : ចូលហ្នឹងគេឲ្យចូលធម្មតាទេ ?

ឆាយវី : បាទ !

អ៊ាង : ប៉ុន្តែ កន្លែងហ្នឹង ឆាយវីឯង ដែលធ្លាប់ស្គាល់ ធ្លាប់ទៅមុនៗមក ធ្លាប់ចូលទៅទេ ?

ឆាយវី : កន្លែងហ្នឹងពីមុនៗមក ខ្ញុំធ្លាប់ដែលចូលដែរ ប៉ុន្តែមិនឃើញមានទាហានទេណា

អ៊ាង : កាលនោះ ចូលទៅលេងពីណា ?

ឆាយវី : ខ្ញុំអត់មានចូលទៅលេងជាមួយអ្នកណាទេ ខ្ញុំដើរតាមដំណើរ

អ៊ាង : ហើយ ចូលទៅអត់មានជួបពីណាទេ ?

ឆាយវី : ជួប ! មានមនុស្សហើយ

អ៊ាង : មានមនុស្សហើយ ?

ឆាយវី : បាទ ! មានមនុស្សហើយ

អ៊ាង : អត់ទាន់មានអ្នកណាមកនិយាយជាមួយឆាយវីឯងទេ ?

ឆាយវី : អត់ទាន់មានទេ គេនៅតែគេ ខ្ញុំនៅតែខ្ញុំ

អ៊ាង : អញ្ចឹង ! ពេលណាទៅ បានមានមនុស្សមកនិយាយជាមួយឆាយវីឯង ?

ឆាយវី : ប្រហែលជាម៉ោង ៧ ភ្លឺច្បាស់ហើយណា

អ៊ាង : អញ្ចឹង ! ឆាយវីឯង ចាំយូរទេ ?

ឆាយវី : ខ្ញុំចាំយូរហើយ ខ្ញុំមកតាំងពីយប់ម្ល៉េះ មកម៉ោង៤កន្លះ គឺខ្ញុំទៅហូបអីនៅក្រៅអញ្ចឹងណា ប៉ុន្តែពេលខ្ញុំប្រហែលជាម៉ោង ៧ ទៅដល់ដើរចុះដើរឡើងៗ ក៏បានជួបជុំគ្នាហ្នឹង ប៉ុន្តែមិនដឹងជានរណាជានរណាទេ អត់ស្គាល់ទេ

អ៊ាង : ហើយយើងមានចាប់អារម្មណ៍អីទេ ?

ឆាយវី : អត់ចាប់អារម្មណ៍ទេ ហើយមិនទាន់ដឹងថា ថ្ងៃហ្នឹងគេឲ្យខ្ញុំធ្វើឬក៏អត់ទេ ខ្ញុំមិនទាន់ដឹងទេ គេអោយខ្ញុំជួប មិនដឹងជួបរឿងស្អីទេ

អ៊ាង : នៅពេលម៉ោងប៉ុន្មានគេមកជួបឆាយវីឯង ?

ឆាយវី : ប្រហែលជាម៉ោង៨

អ៊ាង : ប្រហែលម៉ោង៨ៗ ពីណាមកជួបឆាយវីឯង ?

ឆាយវី : ជួបជុំក្រុមហ្នឹងទាំងអស់

អ៊ាង : ក្រុម ?

ឆាយវី : បាទ ! ប៉ុន្តែ មិនដឹងជានរណា ប៉ុន្តែឃើញមួយហ្វូងទៀតនៅក្រៅ មានតាំងពីទាហាន មានតាំងពីកងអនុសេនាស្អីទាំងអស់

អ៊ាង : ប៉ុន្តែមនុស្សដែលមកជួបនិយាយជាមួយឆាយវីឯងមាននរណាគេមកជាមួយទេ ?

ឆាយវី : មនុស្សមានម្នាក់ មានមាឌធំមកនិយាយជាមួយខ្ញុំហ្នឹង

អ៊ាង : គេនិយាយថាម៉េចទៅ ?

ឆាយវី : គេ គាត់និយាយថា ខ្ញុំក៏មិនដែលមកជួបដែរគាត់មកដល់កន្លែង គាត់ថាមកហើយ ! បាទ ! ខ្ញុំមកហើយ ហើយឯណាបងទៅណា ? ខ្ញុំក៏សួរអ្នកណា ? គាត់ថាឃើញធឿនទេ? ខ្ញុំថាមិនទាន់ឃើញមកទេ...

អ៊ាង : ចុះបន្ទាប់មកទៀត ?

ឆាយវី : បន្ទាប់មកទៀតបានពេលរៀបចេញធ្វើការហ្នឹងឃើញមកជុំគ្នា ប៉ុន្តែមិនដឹងជានរណាខ្ញុំស្មានថាទាហានគេធ្វើការនៅហ្នឹង អីហ្នឹង បានគេប្រាប់ទៅខ្ញុំថា បើការហើយចាំអាហ្នឹងខ្ញុំនិយាយរឿងបោកហើយ ប៉ុន្តែពេលខ្ញុំចេញមក ហ៊ីងប៊ុនហៀង

បានមកជួបខ្ញុំ ក៏មិនជួបស្អីដែរ គ្រាន់តែហុចគ្រាប់អោយខ្ញុំមួយគ្រាប់ គឺគ្រាប់បែក

អ៊ាង : គ្រាប់បែកហ្នឹងម៉ាកអីគេ ?

ឆាយវី : ម៉ាករបស់ចិន អាតូចប៉ុណ្ណេះ បានគេថា បើបែកបានលុយ បើមិនបែកមិនបានលុយទេ ហើយគាត់ដើរហួសទៅ ខ្ញុំក៏មិនចំណាំមុខគាត់ហើយគាត់ក៏មិនចំណាំមុខខ្ញុំដែរ

អ៊ាង : រួចហើយបានអ្នកណានាំឆាយវីឯងចេញ?

ឆាយវី : អ្នកនាំខ្ញុំ គឺម្នាក់ដែលមាឌធំដែលខ្ញុំជួបដំបូង ដែលថាមក ហើយហ្នឹងហើយនោះ ម្នាក់ហ្នឹង

អ៊ាង : ប៉ុន្តែ នៅក្នុងចំណោមមនុស្សដែលថាក្រុមផ្សេងៗហ្នឹង មានឃើញវត្តមានប្រេស៊ីលទេ ?

ឆាយវី : ក្នុងចំណោមនេះ ខ្ញុំក្រឡេកឃើញភ្លែត ហ្នឹងហើយដែលខ្ញុំចំណាំ ដូចថារៀបគប់ទីមួយ...

អ៊ាង : ប៉ុន្តែ នៅក្រោយវត្តបុទុមហ្នឹង កាលដែលមុនមកធ្វើការងារហ្នឹង ឃើញនៅក្នុងចំណោមនេះដែរ ?

ឆាយវី : បាទ ! ឃើញ ឃើញនៅក្នុងចំណោមនោះដែរ សង្កេតមនុស្សដូចជាមិនល្អសោះ ចំណាំ ពេលខ្ញុំទៅណាក៏ដោយក៏ខ្ញុំចំណាំគាត់ដែរ ហើយដល់ពេលខ្ញុំចេញរឹបបាត់វា

អ៊ាង : ហើយមនុស្សមាឌធំហ្នឹង ?

ឆាយវី : បានម្នាក់មាឌធំដែលពាក់មួកនោះអ្នកនាំខ្ញុំចេញ បាទ ! ហើយមករត់ម៉ូតូឌុបនៅនោះ ពីរបីគ្រឿង គេអោយខ្ញុំជិះម៉ូតូឌុបទៅ ខ្ញុំចុះនៅក្រោមដើមមៀន បាទ! ហើយពេលហ្នឹងគេចាប់ផ្តើមហើយ ក្រុមបាតុកម្មបានមកដល់ហើយ ហើយពេលមកដល់វាជិះឆីវឆាប

អ៊ាង : ឆាយវីឯងជិះតែម្នាក់ឯងគត់ទេម៉ូតូហ្នឹង ?

ឆាយវី : ខ្ញុំជិះម៉ូតូឌុប

អ៊ាង : ជិះម៉ូតូឌុបហ្នឹងជិះតែម្នាក់ឯងគត់ ?

ឆាយវី : បាទ ! ម្នាក់ឯង

អ៊ាង : ហើយម៉ូតូឌុបហ្នឹងឈប់អោយឆាយវីឯង ឬក៏ឆាយវីឯងកុម្ម៉ង់ ?

ឆាយវី : អត់ទេ ! ម៉ូតូឌុបគេឈប់ ហើយឈរនៅកន្លែងហ្នឹង

អ៊ាង : អញ្ចឹង! បានន័យថា មនុស្សហ្នឹងមិនមែនអ្នកម៉ូតូឌុបទេ

ឆាយវី : ខ្ញុំក៏សង្ស័យអញ្ចឹងដែរ ថាម៉ូតូឌុប គេថាអោយឈប់ត្រង់ណាគឺឈប់ត្រង់ហ្នឹង ហើយពេលខ្ញុំឈរមិនទំនងក៏ឆ្លងកាត់ ហើយខ្ញុំក៏ដើរទៅក្រោមដើមអំពិល ស្រាប់តែខ្ញុំងាកមកវិញ ឃើញអាប្រេស៊ីលវាគប់ ហើយមិនដឹងវាគេចទៅណាទេ ហើយ ក៏ប៉ុន្មាននាក់ចេញពីណាមកណាគប់ ត្រង់ថាវាចេញពីណាមក ណាខ្ញុំក៏មិនបានដឹងទេ រឿងគ្រាប់ដែលផ្ទុះហ្នឹងមិនដឹងចេញពីណាទេ ខ្ញុំអត់បានដឹងទេ អាប្រេស៊ីលគេគប់ទៅ

អ៊ាង : អាប្រេស៊ីលច្បាស់ជាងគេ ?

ឆាយវី : បាទ ! ច្បាស់ជាងគេ អាប្រេស៊ីល គ្រាន់តែងាកខ្លួនទៅ ខ្ញុំក៏ចាប់ផ្តើមទៅខាងសួនច្បារនោះទៅវិញ រួចរត់ចូលវត្តបុទុម ទៅពីវត្តបុទុមហ្នឹងទៅមានទាហានគេយាម មានពួកសំណាញ់ ខ្ញុំរត់ទៅ មានគេរត់តាមពីក្រោយ ខ្ញុំក៏ចូលវត្តចូលក្នុងវត្តមានឃើញទាហាននៅក្នុងវត្ត ។

អ៊ាង : ពេលឆាយវីឯងបោក បោកគ្រាប់ទីប៉ុន្មាន ?

ឆាយវី : ខ្ញុំគ្រាប់ទី៤

អ៊ាង : រួចហើយ បោកភ្លាម រត់ ?

ឆាយវី : បាទ ! រត់បណ្តោយ

អ៊ាង : ហើយចូលវត្តមុនគេ ?

ឆាយវី : ខ្ញុំចូលវត្តមុនគេ ហើយក្រុមរបស់គេមិនដឹងរត់ទៅណាៗ ខ្ញុំមិនដឹង ឬក៏គេចូលចន្លោះឯណាក៏មិនដឹងដែរណា ប៉ុន្តែខ្ញុំរត់មុនគេ...

អ៊ាង : រត់ ! រត់កាត់វត្តតែម្តង ?

ឆាយវី : អត់ទេ! រាងបញ្ឆិត បញ្ឆិតវត្ត មានទាហានគេយាមហ្នឹង ខ្ញុំក៏...

អ៊ាង : ចូលតាមប្រឡោះណា?

ឆាយវី : ចូលចំហៀងវត្តទៅវិញ

អ៊ាង : ចំហៀងវត្ត ផ្លូវ? អត់បានចូលកាត់តាមវត្តទេ?

ឆាយវី : អត់ទេ ! ដូចគប់ត្រង់នេះ ខ្ញុំចូលបញ្ឆិតវត្ត

អ៊ាង : គូសប្លង់សិន នេះផ្លូវមុខវត្ត នេះវត្ត ហើយទាហានគេវាយរហូត ហើយបន្ទាប់មក មិនចប់ខ្សែត្រៀមទាហាន ទាហានវាយកាត់មុខវត្ត

ឆាយវី : ហ្នឹង ! កាត់វត្ត ផ្លូវច្រកវត្តហ្នឹង

អ៊ាង : ចុះវត្ត ! ចេញតាមផ្លូវណា ? វត្តមានរបង

ឆាយវី : បាទ ! មានរបង

អ៊ាង : ចេញទ្វារវត្ត ចេញទ្វារមួយណា ?

ឆាយវី : ទ្វារក្រោយវិញ

អ៊ាង : ទ្វារក្រោយ?

ឆាយវី : បាទ !

អ៊ាង : មានផ្លូវមួយ រួចបានចូលក្នុងផ្លូវមានឃើញមនុស្សប៉ុន្មាននាក់ ?

ឆាយវី : មានឃើញតែទាហាន អត់មានឃើញប្រជាជនទេ

អ៊ាង : ទាហានប្រហែលប៉ុន្មាននាក់ ?

ឆាយវី : ទាហានមានប្រហែល... ច្រើនដែរតើប្រហែលម្ភៃ

សាម ម្តែនាក់អីអញ្ចឹង ខ្ញុំមិនបានរាប់ដែរ

អ៊ាង : ប៉ុន្តែ ទាហានក៏អត់មានសួរនាំឆាយវីឯងថា មកពីណាមក ពីណីអី ?

ឆាយវី : អត់មានសួរទេ ប៉ុន្តែដូចថា ជួយគេចាប់ផ្តើមជួបសង្គ្រាម ដូចថា រត់ចុះឡើងៗ ដូចខ្ញុំដែរ រត់ចុះឡើងៗ ដូចខ្ញុំដែរ បាទ ! គេ ដឹងថា ខ្ញុំហ្នឹងស៊ីវិលដែរទេ...

អ៊ាង : ហើយគេអត់មានសួរនាំអីទេ

ឆាយវី : អត់មានសួរនាំអីទេ

អ៊ាង : ហើយពេលណាទៅបានឆាយវីឯងចេញពីកន្លែងហ្នឹង ?

ឆាយវី : ខ្ញុំនៅប្រហែលជាប្រាំនាទី ខ្ញុំមើលឃើញសភាពការណ៍ ដូចជាមិនស្រួល នៅក្នុងចំណោមទាហានប៉ុន្មាននាក់ហ្នឹង ខ្ញុំមើលមុខ ដឹង ក៏រត់ចេញទៅ

អ៊ាង : ហើយឆាយវីឯងមានលាពួកហ្នឹងទេ ?

ឆាយវី : អត់មានលាគេទេ គេក៏មិនបានសួរខ្ញុំដែរ ខ្ញុំក៏មិនសួរគេដែរ

អ៊ាង : ហើយនៅពេលហ្នឹង នៅពេលដែលឆាយវីឯងបើទទួល លុយបានមួយពាន់ដុល្លារហ្នឹង តើមានទឹកចង់បានលុយប្រាំបួនពាន់ ដុល្លារមកបង្គ្រប់ទៀតទេ ?

ឆាយវី : ចិត្តគឺចង់ដែរបង ចិត្តរឿងលុយចង់ ប៉ុន្តែមើលទៅសភាព គឺវាមិនស្រួល ខ្ញុំក៏មិនចង់បានដែរ

អ៊ាង : លែងចង់បាន ?

ឆាយវី : បាទ ! លែងចង់បាន

អ៊ាង : ហើយក៏ជិះម៉ូតូចេញទៅ ?

ឆាយវី : បាទ ! ជិះម៉ូតូចេញទៅ

អ៊ាង : ជិះម៉ូតូចេញហើយទៅណាទៀត ?

ឆាយវី : ខ្ញុំឡើងទៅកំបូល បាទ ! ហើយខ្ញុំចេញពីកំបូលមកក្នុងក្រុង

អ៊ាង : ទៅកំបូល ទៅកំបូលថ្ងៃប៉ុន្មាន ?

ឆាយវី : ទៅក្នុងថ្ងៃហ្នឹងហើយបង

អ៊ាង : ទៅកំបូល ?

ឆាយវី : ខ្ញុំក៏ទៅយកខោអាវក៏ចេញមក

អ៊ាង : អត់មាននៅកំបូលទៀតទេ ?

ឆាយវី : អត់មាននៅទេ រហូតតាំងពីពេលហ្នឹងមក

អ៊ាង : ចេញពីកំបូលមានទៅណាទៀត ?

ឆាយវី : ខ្ញុំចេញពីកំបូល ខ្ញុំមកនៅបឹងកក់ ប្រហែលមួយយប់ពីរយប់ បានខ្ញុំចេញពីហ្នឹងទៅកំពុងចាម

អ៊ាង : នៅបឹងកក់នៅជាមួយពីណា ?

ឆាយវី : ខ្ញុំនៅផ្ទះជួល

អ៊ាង : នៅផ្ទះជួល មានប្រពន្ធកូនអីទេ ?

ឆាយវី : អត់មាននៅទេ...

អ៊ាង : រួចហើយ បានចេញពីបឹងកក់ទៅណា ?

ឆាយវី : ខ្ញុំទៅកំពង់ចាមបណ្តោយ

អ៊ាង : ចុះម៉ូតូលក់នៅឯណា ?

ឆាយវី : លក់នៅកំពង់ចាម

អ៊ាង : លក់អោយអ្នករកស៊ី ?

ឆាយវី : លក់អោយអ្នករកស៊ី

អ៊ាង : ចេញពីកំពង់ចាមទៅនៅឯណា ?

ឆាយវី : ខ្ញុំទៅដល់ក្រចេះ

អ៊ាង : ទៅដល់ក្រចេះផ្ទះពីណា ?

ឆាយវី : ផ្ទះប្អូន

អ៊ាង : ថ្ងៃដែលឆាយវីបោកគ្រាប់បែកហ្នឹង ថ្ងៃហ្នឹង ឆាយវីឯង ស្លៀកពាក់ខោអាវអី ?

ឆាយវី : ខ្ញុំស៊ីវិល

អ៊ាង : ស៊ីវិល !

ឆាយវី : អាវដៃវែង និងអាវយឺតក្នុង នេះ អាវពណ៌ហ្នឹង ប៉ុន្តែអាវដៃវែង ពណ៌ហ្នឹង

អ៊ាង: ពណ៌ហ្នឹង ! ពណ៌ដូចគ្នាហ្នឹង ?

ឆាយវី : ពណ៌ដូចគ្នាហ្នឹង ប៉ុន្តែពាក់អាវយឺតក្នុង

អ៊ាង : រួចចុះគ្រាប់បែក គ្រាប់បែកសៀតយ៉ាងម៉េច ?

ឆាយវី : ខ្ញុំដាក់នៅចង្កេះ

អ៊ាង : អាគ្រាប់បែកចិនប៉ុណ្ណា ?

ឆាយវី : តូច

អ៊ាង : ពេលដែលឆាយវីឯងចេញទៅបោកបែបហ្នឹង មាន មនុស្ស គេតាមទេ ?

ឆាយវី : មាន មានគេតាម ប៉ុន្តែមិនដឹងថា ឬមួយគេដើរតាម ជាមួយខ្ញុំ ឬមួយគេទៅណា ប៉ុន្តែផ្លូវដែលខ្ញុំទៅណា គេទៅហ្នឹង ដែរ ប៉ុន្តែមិនមែនថាទៅនេះទៅនោះ ប៉ុន្តែខ្ញុំឆ្លងមក គេឆ្លងមក ដែរ ប៉ុន្តែពេលឆ្លងបាត់គេ ខ្ញុំនៅក្រោមដើមអំពិល

អ៊ាង : ហើយអ្នកបោកគ្រាប់ទីពីទីបីហ្នឹង ឆាយវីឯងអត់ដឹងថា ចេញ ពីនៅកន្លែងណាកន្លែងណាទេ ?

ឆាយវី : អត់ដឹងទេ ! ប៉ុន្តែអាមួយលើ អានេះហ្នឹងគឺចេញពី របង អែបសភាមក

អ៊ាង : អាហ្នឹងគ្រាប់ទីមួយ ?

ឆាយវី : បាទ !

អ៊ាង : បានឃើញអាប្រេស៊ីលហ្នឹង ?

ឆាយវី : បាទ ! បានឃើញប្រេស៊ីលហ្នឹងតែម្តង។ ខ្ញុំមិនទាន់ខ្ញុំមិនស្គាល់ឈ្មោះ ប្រេស៊ីលហ្នឹងផង ប៉ុន្តែចំណាំមុខ ក្នុងចំណោមទៅហ្នឹង ឃើញអានោះមួយ ប៉ុន្តែបើតាមខ្ញុំមើលទៅ ដូចជាអាក្រក់

អ៊ាង : គ្រាន់តែឃើញ បានសំគាល់ជាងគេ អញ្ចឹងទៅ

ឆាយវី : បាទ ! ខ្ញុំក៏មើលទៅ ងាកទៅឃើញវា ដឹងថាអាហ្នឹងឯងដល់មានរឿងទៅខ្ញុំក៏ចាប់ផ្តើម...

អ៊ាង : ហើយទើបតែមុន មុនចេញ អាព្រឹកថ្ងៃ មុនចេញពីវត្តបទុមដែល ពេលដែល ហ៊ីង ប៊ុនហៀងហុចគ្រាប់បែកអោយ តើហ៊ីង ប៊ុនហៀងផ្តាំថាម៉េច ។

ឆាយវី : ផ្តាំថា ទាល់តែបែកបានអោយលុយ បើមិនបែកទេអត់បានលុយទេ

អ៊ាង : ហើយពេលនោះ ឆាយវីឯងមានចាំទេ ពេលដែលគាត់ជួបឆាយវីឯង ហុចគ្រាប់បែកអោយហើយ គាត់បាន ដើរទៅណាទៀត ?

ឆាយវី : គាត់ដើរ ខ្ញុំក៏ចេញទៅ ប៉ុន្តែមិនបានសំណេះសំណាលឬមួយសួរខ្ញុំពីអ្វីមួយនោះ ក៏មិនបានសួរដែរ ព្រោះថា គ្រាប់បែកបែកបានបានលុយ មិនបែកមិនបានលុយទេ ធ្វើម៉េចម៉ារួចខ្លួន កំណត់ម៉ារួចខ្លួន...

អ៊ាង : ហើយតើសង្កេតឃើញគាត់ដើរទៅជួបអ្នកណា ?

ឆាយវី : អត់ជួបនរណាទេ

អ៊ាង : គឺដើរទៅបាត់ !

ឆាយវី : បាទ ! ព្រោះពួកគេមានក្រុមរបស់គេ ព្រោះខ្ញុំមិនមែននៅក្នុងក្រុមជាមួយគេ គេខ្លាចខ្ញុំ ខ្ញុំក៏មិនដឹងរឿងគេដែរ គ្រាន់ថាពេលទៅណាមកណា គ្រាន់តែចាំមើល...

អ៊ាង : អញ្ចឹង ពេលហ្នឹង គេអត់មានបញ្ជាថា អោយឆាយវីឯងបោកគ្រាប់ទីប៉ុន្មាន ?

ឆាយវី : ទេអត់មានទេ អត់មានបញ្ជាទីប៉ុន្មាន

អ៊ាង : បានន័យថា ឆាយវីឯងពួគេបោកខឹងៗ

ឆាយវី : ខឹងៗ រាងចន្លោះវែងបានខ្ញុំដាក់ មិនមែនខឹងៗនោះទេ វារាងដូចឃ្លាត

អ៊ាង : ឥឡូវ ! ខ្ញុំចង់ដឹងថា សំឡេងគ្រាប់ពួយ៉ាងម៉េច ពេលដែលគេ...

ឆាយវី : ពួខឹងៗ ទើបខ្ញុំបន្តមួយដង្ហើម មិនមែនថាមួយដង្ហើមមួយឃ្លាត

អ៊ាង : មានគ្រាប់ទីបី ទីបី ចាំមើណា មានគ្រាប់ទីមួយទីពីរ ទីបីពួយ៉ាងម៉េចដែរ ?

ឆាយវី : ពេលនោះខ្ញុំអត់បានផ្ទៀង ខ្ញុំអត់បានផ្ទៀង ព្រោះកន្លែងនោះកំពុងតែជ្រួលច្របល់

អ៊ាង : ពេលដែលឆាយវីឯងទៅដល់កន្លែងបាតុកម្ម ពេលនោះតើពីណា នៅកំពុងនិយាយ ?

ឆាយវី : ពេលកំពុងបាតុកម្ម ខ្ញុំឃើញ លោកប្រធានកំពុងតែដៃជើងច្រងេងច្រងាង គាត់កំពុងនិយាយពីបញ្ហាអ្វី ខ្ញុំអត់ដឹងដែរ ខ្ញុំនៅឆ្ងាយ

អ៊ាង : កាន់ម៉េក្រូ ?

ឆាយវី : បាទ !

អ៊ាង : អញ្ចឹងពេលដែលផ្ទុះគ្រាប់បែក ពីណាអ្នកនិយាយ ?

ឆាយវី : ពេលគប់គ្រាប់បែកខ្ញុំមិនដឹងទេ ខ្ញុំមិនបានមើលនរណាទាំងអស់

អ៊ាង : គ្រាន់តែចាំ សំរាប់ធ្វើការងារហ្នឹងឯង

ឆាយវី : បាទ ! ធ្វើការងារ សំរាប់តែលុយតែប៉ុណ្ណឹង

អ៊ាង : ហើយ ! តើពីណាអ្នកណាត់អោយឆាយវីឯង មក...?

ឆាយវី : គេអ្នកណាត់នោះ គឺ ពេលនោះ ស្អី គាត់ឈ្មោះអីហ៊ីង ប៊ុនហៀង

អ៊ាង : ណាត់ពេលណា ?

ឆាយវី : ណាត់ពេលក្នុងឡាន

អ៊ាង : ពេលក្នុងឡាន

ឆាយវី : បាទ ! ហើយគាត់ក៏មិនបានប្រាប់ ធឿនគេគេប្រាប់ខ្ញុំតែខ្ញុំមិនចាប់ភ្លឹកកន្លែងណា។ ក៏ខ្ញុំអត់ដឹងដែរ ទាល់តែសួរលោកធឿនទើបបានដឹង បាទ !

អ៊ាង : ប៉ុន្តែ នៅមុខវត្តបុទុមគេអត់ប្រាប់ថាចូលយ៉ាងម៉េចទេ ?

ឆាយវី : ...

អ៊ាង : គាត់អត់មានប្រាប់ថា រកឆាយវីឯង ហើយគ្រាន់តែនៅក្រោយវត្តបទុម ឆាយវីឯងដឹងតែម្តង ?

ឆាយវី : ពេលហ្នឹង គាត់ទៅក្រោយ ប៉ុន្តែគាត់ទៅឈរដូចថាឃើញបណ្តោយទៅ ឃើញកន្លែងបែកជាបីហ្នឹង ទៅឃើញ ទៅឃើញបណ្តោយ ទៅឃើញមែន ទៅកន្លែងហ្នឹង ទៅឈប់កន្លែងហ្នឹងទៅ ទៅឃើញទាហានអីយាម នៅត្រង់ហ្នឹងឯង ហើយឈប់ កន្លែងហ្នឹងទៅ ។

អ៊ាង : អូ ! កន្លែងផ្លូវភ្លោះហ្នឹង ?

ឆាយវី : បាទ ! នៅត្រង់ហ្នឹងនៅឃើញទាហានអី នៅយាមឈប់ត្រង់ហ្នឹងទៅ ។

អ៊ាង : ហើយ ដល់ពេលហើយ ក៏គេចបាត់ទៅលក់ម៉ូតូបានថ្លៃប៉ុន្មាន ?

ឆាយវី : ជិត ប្រាំបីរយ ខ្ញុំបានលក់បាន ប្រាំពីររយប៉ែត លក់នៅកំពង់ចាម

អ៊ាង : តាំងពីមកពីឥណ្ឌូនេស៊ីវិញមុនមួយខែមុនគប់គ្រាប់បែក ឆាយវីឯងចូលលេងទួលក្រសាំង បានប៉ុន្មានដង ?

ឆាយវី : ខ្ញុំបានទៅតែម្តងទេ

អ៊ាង : ម្តងហ្នឹង

ឆាយវី : ទៅលេងម្តង ទៅផ្លូវការហ្នឹងម្តង ឡើងពីរដងទៅម្តង ហ្នឹងទៅអត់ជួបវានេះទេ បានទៅពេលក្រោយគេនិយាយ ពីរឿងខ្ញុំអញ្ចេះអញ្ចោះទៅ វាៗចាប់ភ្ញឹក ទៅថ្ងៃក្រោយលេងជាមួយវាហ្នឹង ជួបវាហ្នឹង អញ្ចឹងបានក្រុមពួកគេហ្នឹង គេថាអោយខ្ញុំទៅនៅជាមួយគេអញ្ចឹង អញ្ចេះអញ្ចោះ ក៏ចាប់ផ្តើមពីពេលនោះឯង ។

អ៊ាង : ចំណែកធឿនស្គាល់ឆាយវីពីពេលណា ធឿន ?

ធឿន : ស្គាល់យូរហើយៗ មួយឆ្នាំពីរឆ្នាំហើយ តាំងពីមកពីឥណ្ឌូ-នេស៊ី

អ៊ាង : ស្គាល់គ្នា ?

ធឿន : បាទ !

អ៊ាង : ស្គាល់គ្នាធ្លាប់ស៊ីផឹកជាមួយគ្នា ?

ធឿន : បាទ ! ធ្លាប់ស៊ីផឹកដេកនៅជាមួយគ្នាហ្នឹង ចេញចូលផ្ទះសំបែងអី

អ៊ាង : ប៉ុន្តែធឿនឯងស្គាល់ប្រេស៊ីលច្បាស់ទេ ?

ធឿន : ច្បាស់បង !

អ៊ាង : ស្គាល់ច្បាស់ !

ធឿន : បាទ !

អ៊ាង : ហើយធ្លាប់និយាយអីគ្នាទេ ?

ធឿន : ធ្លាប់ !

អ៊ាង : ធ្លាប់និយាយទេ ?

ធឿន : ធ្លាប់បង ហើយចេញចូលចេញចូលហ្នឹង

អ៊ាង : ហើយស្គាល់ផ្ទះ ?

ធឿន : ស្គាល់ផ្ទះទៀត

អ៊ាង : ហើយស្គាល់មុខម្តាយទេ ? ស្គាល់មុខឪពុកម្តាយប្រេស៊ីលទេ?

ធឿន : អត់ស្គាល់ទេ តែផ្ទះស្គាល់

អ៊ាង : ស្គាល់ ! ហើយខ្ញុំដូចឆ្ងល់ ធឿនឯងនឹកឃើញយ៉ាងម្តេចបានយកព័ត៌មានរឿងឆាយវីបោកគ្រាប់បែកមកប្រាប់គាត់ ?

ធឿន : ខ្ញុំមិននឹកឃើញយ៉ាងម្តេចមុនដំបូង ពេលដំបូងហ្នឹងអាពេលកើតហេតុហើយ កើតហេតុហើយហ្នឹង ខ្ញុំឮកាសែត និយាយអញ្ចេះអញ្ចុះថា ទំលាក់កំហុសមកលើឯកឧត្តម សម រង្ស៊ី ហើយខ្ញុំនេះចេះតែអង្គុយអស់សំណើច តែរយៈពេលហ្នឹង ខ្ញុំដឹងរឿងគេច្បាស់ណាស់បងដល់ខ្ញុំដឹងដឹងរឿង គេច្បាស់ ខ្ញុំចេះតែពិចារណាថ្ងឹងថ្ងែង ដល់ថ្ងឹងថ្ងែងហើយ ក្រោយមកទៀត ក្រោយមកដឹងបាត់អាពួកនេះ ដល់បាត់ពួកនេះ ខ្ញុំចេះតែរកមើលវា មិនដឹងជាទៅណាមកណា រកមិនឃើញ ស្អីមិនឃើញ ខ្ញុំក៏ទៅផ្ទះអាប្រេស៊ីល ដល់តែទៅសួរ សួរថាឯងឃើញអាមួយប្រជ្រុយដែលជួបវាដែរទេ ? វាថាអត់ដែលជួបទេ ខ្ញុំសួរថាចុះពួកហ្អែងប៉ុន្មាននាក់ហ្នឹងទៅណាអស់ហើយ វាថាទៅអស់ហើយបងអើយ ទៅណាអស់ ? វាថាគេយកទៅកំពុងសោមអស់ហើយអាហ្នឹងឈប់និយាយឮហើយ បានហៅវាមកសួរ គ្រាន់តែហើយអីចឹង ហើយខ្ទង់ម៉ោង១១វាដឹកខ្ញុំចេញពីផ្ទះនោះទៅ ទៅដល់ទួលក្រសាំង គេដឹកយន្តហោះទៅកំពុងសោម

អ៊ាង : ចុះពួកហ៊ីង ប៊ុនហៀង អត់ស្គាល់ផ្ទះប្រេស៊ីលទេ ?

ធឿន : បាទ !

អ៊ាង : អត់ស្គាល់ផ្ទះប្រេស៊ីលទេឬ ?

ធឿន : ហ៊ីង ប៊ុនហៀងស្គាល់ បង

អ៊ាង : ស្គាល់ផ្ទះប្រេស៊ីលដែរ

ធឿន : បាទ ! ស្គាល់

អ៊ាង : ចុះពេលដែលប្រេស៊ីលរត់ ម៉េចមិនតាមរកដល់ផ្ទះ ?

ធឿន : ពេលដែលរត់វា វានៅឯណោះ ទាំងអស់គ្នាទៅកំពង់សោម ដល់ពេលរត់មក រត់មកខ្ញុំ ទៅសួរហ្នឹងក៏នេះដែរស្ងាត់ៗដែរទៅ ដល់វាមិនចង់ជួបខ្ញុំទេ អ្នកផ្ទះគេចេះលាក់អញ្ចេះអញ្ចុះដល់ខ្ញុំទៅសួរ ទៅដល់ស្រាប់តែទៅវាក់អើ វាក់អើវាប្រុងគេចខ្ញុំដល់ប្រុងគេចខ្ញុំ ខ្ញុំថាឯងមកនេះ សួរបន្តិច វាក៏ចេញមកជួបខ្ញុំក៏សួរ សួរតាមដំណើរម៉េញហ្នឹង សួររកវាហ្នឹងថាកាលទៅៗ៦នាក់ទេ ? អាម្នាក់ហ្នឹងអត់អត់ឃើញទេបង បាត់តាំងពីថ្ងៃកើតហេតុហ្នឹងរហូត ដល់រួចខ្ញុំថា បើអញ្ចឹងហ្អែងម៉េចមិនគេចខ្លួនទៅ ឯងមកនៅផ្ទះធ្វើអ្វី ? វាថាខ្ញុំកំពុងតែគិត បន្តិចទៀតខ្ញុំនឹងសុំគេធ្វើទាហានធ្វើអី ខ្ញុំថាបើធ្វើទាហានធ្វើទៅ ម៉េចៗការពារខ្លួនអោយរស់សិនវើយ ហើយចាំបន្តិចទៀតមើលវាយ៉ាងម៉េចផុតពីហ្នឹងខ្ញុំក៏ទៅផ្ទះ ទៅផ្ទះឮប្រពន្ធខ្ញុំថាអ្នកធ្វើការជាមួយ មករកខ្ញុំ រកមានការអី ? គេថាអត់ដឹង មកពីរបីនាក់ជិះម៉ូតូ ហើយបើបងឯងមកអោយទៅកន្លែងធ្វើការ ។ ខ្ញុំថាអត់ស្រួលទេ មិនបានធ្វើតែដឹងរឿងហើយអាគេធ្វើគេយកទៅអស់ហើយៗ តែទៅប្រាកដជាងាប់ហើយ ។ ខ្ញុំអត់មាត់រួចខ្ញុំក៏ចេញពីផ្ទះ ខ្ញុំប្រាប់ប្រពន្ធខ្ញុំថា បើអ្នកណាមករកអញថាអត់ដឹងទៅណាទេ បើគេសួរថាលែងគ្នាហើយ មិនទៅណាទេខ្ញុំប្រាប់ប្រពន្ធខ្ញុំអញ្ចឹង ខ្ញុំគេចរហូត ខ្ញុំទៅនៅកំពង់ចាមរកស៊ីដឹកឈើដឹកអី ជញ្ជូនឈើជញ្ជូនអីអោយគេបានប៉ុន្មានជើង ខ្ញុំធ្វើបានពីរជើង ទៅរកអានេះ ខ្ញុំទៅរកអានេះ ដល់ទៅរកអានេះ គិតថាផ្លូវទឹក អញរកស៊ីឈើចូលកំពង់ចាម ប្រាកដជាគេស្គាល់ខ្ញុំគេស្គាល់ខ្ញុំច្បាស់

ណាស់កំពង់ចាម ដល់ខ្ញុំថាអាហ្នឹងរឹតតែបញ្ចេញមុខទៀតហើយ ! ខ្ញុំក៏ឈប់ ដល់ឈប់ ខ្ញុំមកនៅជាមួយប្រពន្ធចុងនៅកំពង់ចាមហ្នឹង នៅឆ្ងាយណាស់នៅព្រៃឈរជាប់ព្រំប្រទល់កងមាសនៅ ជាមួយប្រពន្ធខ្ញុំរកត្រីរកអីហ្នឹងជាមួយគេហ្នឹងទៅ ដាក់មងដាក់អី នៅផ្ទះហ្នឹងបាយជ្រូកអីនៅផ្ទះហ្នឹងរហូត ដល់ក្រោយមក បានខ្ញុំមកផ្ទះ មកផ្ទះហ្នឹងបានអាមួយ ត្រូវជាក្មួយខ្ញុំ ដែលដឹកខ្ញុំទៅ ដល់វានិយាយថាដល់ហើយរឿងបោកគ្រាប់បែកហ្នឹង

អ៊ាង : ហើយបានជួបនឹងឆាយវីដែរ ?

ធឿន : បាទ !

អ៊ាង : ...

ធឿន : ជួបហើយបង

អ៊ាង : ជួបឆាយវីនៅឯណា ?

ធឿន : នៅក្រចេះ

អ៊ាង : នៅក្រចេះ ?

ធឿន : បាទ ! នៅក្រចេះ

អ៊ាង : ចុះពេលហ្នឹងឆាយវីឯងមានបានចូលមកភ្នំពេញវិញទេ ?

ឆាយវី : អត់ចូលទេ ! នៅក្រចេះរហូត

អ៊ាង : នៅក្រចេះរហូតអត់ដែលមកភ្នំពេញទេ

ឆាយវី : បាទ ! អត់ដែលទេ

អ៊ាង : ចុះពេលជួបប្រេស៊ីល ជួបនៅឯណា ?

ឆាយវី : ពេលជួបប្រេស៊ីល ជួបនៅកន្លែងធ្វើការ

អ៊ាង : ជួបប្រេស៊ីលទៀត ជួបលើកក្រោយដែលគាត់បានគប់គ្រាប់ហើយ បានជួបប្រេស៊ីលម្តងតើជួបនៅឯណា ?

ឆាយវី : ធឿនគេជួបប្រេស៊ីល ប្រេស៊ីលប្រាប់ធឿនថា គេលួចរត់

សូម្ប៉ា : ឈប់សិន ! ខ្ញុំសុំសួរមួយ មិញថា ប្រេស៊ីលទៅផ្ទះធឿនទៅជួបអ្នកណា ដែលនិយាយថា អ្នកទាំងប្រាំមួយនាក់ហ្នឹងចេញទៅបាត់ហ្នឹង ?

ឆាយវី : ប្រេស៊ីលប្រាប់ខ្ញុំ

សូម្ប៉ា : អញ្ចឹង ម៉េចក៏ប្រេស៊ីលអត់ទៅជាមួយគេអញ្ចឹង ?

ឆាយវី : បាទ ! ទៅដែរ តែរត់រួចមកវិញ...

អ៊ាង : ធឿនឯង តាំងពីថ្ងៃដែលបែកចេញឆាយវីហ្នឹង ដែលត្រឡប់ទៅវិញទេ ?

ធឿន : អត់ផង ! បង អត់ដែលទៅសោះ ទូរស័ព្ទអីអត់ដែរ

អ៊ាង : នឹកឃើញម៉េចបានអត់ទៅ ?

ធឿន : ព្រោះខ្ញុំដឹងរឿងអាគេយកទៅ ដឹងរឿងធ្វើក៏ស្លាប់ ធ្វើហើយស្លាប់ ហើយខ្ញុំដឹងរឿងគេខ្ញុំប្រាកដជាខ្ញុំស្លាប់ដែរហើយ ហើយគេតាមអោយទៅកន្លែងកុំខាន ខ្ញុំចេះតែគេចៗខ្លួនទៅ រហូតមក

សូម្ប៉ា : ហើយពេលណាដែលធឿនឯងនឹកឃើញថា ចង់មកជួប សម រង្ស៊ី ?

ធឿន : ក្រោយមក យូរដែរ ប្រហែលជាប្រាំបីប្រាំបួនខែ បានទៅជួបមនុស្សម្នាក់ថា នៅអង្គរក្សព្រះអង្គម្ចាស់ និយាយប្រាប់ដំណើរទំនងថា ទៅជួយបំភ្លឺឯកឧត្តម សម រង្ស៊ី ទៅក្រែងលោមានជាប់ឆ្នោតជាប់អីទៅ យើងអាចស្រួលខ្លួនបន្តិចហើយបើថាមិនទៅជួយសំរួលទេ ជួយបំភ្លឺគាត់ទេគេចេះតែចោទទំលាក់លើគាត់ថាគាត់នាំបាតុកម្ម ហើយសំលាប់មនុស្ស

សូម្ប៉ា : អង្គរក្សព្រះអង្គម្ចាស់ហ្នឹង ធឿនឯងស្គាល់តាមរយៈអ្នកណា?

ធឿន : តាមក្មួយខ្ញុំ ក្មួយខ្ញុំរត់ម៉ូតូឌុប

អ៊ាង : ហើយពេលជួបលោកហ្នឹង ធឿនឯងប្រាប់គាត់ថាម៉េច ?

ធឿន : បាទ !

អ៊ាង : ជួបអង្គរក្សអង្គម្ចាស់ រណឫទ្ធិ

ធឿន : ទៅដល់វាយកខ្ញុំទៅផ្ទះហ្នឹងទាំងយប់ ខ្ញុំថាមិនដឹងជានិយាយថាម៉េចទេ បានក្មួយខ្ញុំប្រាប់ថា បើសិនជាយើងទៅជួយបំភ្លឺជាមួយឯកឧត្តម សម រង្ស៊ី ទៅ យើងអាចសុខខ្លួនហើយយើងអាចធ្វើអីគេមិន កើតទេ អាចបានសុខស្រួលខ្លះ ហើយក៏ពិភាក្សាគ្នាជាមួយកូនចៅច្រើន ហើយខ្ញុំក៏គិតឃើញថាប្រថុយអីចឹង តែខ្ញុំថា ខ្ញុំមិនមែនអ្នកធ្វើទេ គ្រាន់តែថា ខ្ញុំអ្នកដឹងរឿងព្រោះខ្ញុំនៅក្នុងអង្គរក្ស ខ្ញុំដឹងរឿងទាំងអស់ ធ្វើអីៗហ្នឹង ខ្ញុំដឹងតែខ្ញុំចង់ទៅបំភ្លឺថា ដល់ខ្ញុំមកឈរមុខហ្នឹងវាចូលទៅជួប ខ្ញុំមិនទុកចិត្តដែរហ្នឹងឃើញអ្នកខ្លះមើលមុខ ខ្ញុំប្រុងឡើងម៉ូតូទៅវិញហើយហ្នឹង ដល់រួចបានគេអោយចូល បានខ្ញុំ ខ្ញុំដាច់ចិត្តថាដើរចូលទៅ តែដល់ចូលទៅជួបបងនៅកន្លែងហ្នឹង តាំងពីថ្ងៃហ្នឹងមក ខ្ញុំដូចជារាងធូរចិត្តបន្តិច ខ្ញុំថា រឿងហ្នឹង អញ្ចឹង ខ្ញុំសុខចិត្តទៅស្រាយបំភ្លឺ ហើយខ្ញុំក៏នៅផ្ទះ ក៏មិនសុខដែរព្រោះគេតាមរកជដែលទៅដូចចោរអញ្ចឹង ទៅមួយភ្លែតៗ

អ៊ាង : ប៉ុន្តែខ្ញុំចង់សួរមួយ ឆាយវី នៅពេលធឿនបានជួបឆាយវីឯងចុងក្រោយនេះ រហូតថ្ងៃនេះ តើឆាយវីឯងមានក្នុងចិត្តមានភ័យថាខ្លាចមានទោសទេ ខ្លាចមានទោស ?

ឆាយវី : រឿងធឿន គេទៅជួបខ្ញុំគេនិយាយរឿងពីបញ្ហា រឿងគណបក្ស សម រង្ស៊ីអញ្ចេះមួយៗ ណាបងណា ខ្ញុំកំពុងតែគិតខ្ញុំកំពុងតែទាមទារ ដូចថាស្មោះត្រង់ ហើយដូចថារកសន្តិភាពក្នុងខ្លួនផងណាមួយរឿងប្រទេសជាតិយើងផង ព្រោះខ្ញុំធ្លាប់រៀនរូបមន្ត ប៉ុន្តែអារឿងច្បាប់ខ្ញុំមិនដែលចេះទេ ព្រោះតែខ្ញុំក៏មិនដែលគិតឃើញថានៅកន្លែងនោះអោយគេចូល ចូលក្នុងផ្សារ ខ្ញុំ

មិនហ៊ានចូលទេ ខ្ញុំមិនទាន់ទុកចិត្តធឿននោះទេ អ្នកណាក៏ខ្ញុំមិនទុកចិត្តពេលនោះ ខ្ញុំលែងទុកចិត្តវា ហើយវាលែងទុក ចិត្តមួយសារ ដូចថា មួយញាវម៉ាបន្តិចហ្នឹងឯងខ្លាចធឿននេះ នាំខ្ញុំទៅដាក់ក្នុងពេលក្រុមវានោះរួច ខ្ញុំក៏ជាប់អញ្ចេះខ្លាចខ្ញុំចាញ់នយោបាយ ត្រង់ហ្នឹងបានខ្ញុំសង្កេតតាមដានវាទៅ វាក៏មិនមែន ខ្ញុំក៏ប្រថុយខ្លួនចូលក្នុងគណបក្សសម រង្ស៊ីហ្នឹង

អ៊ាង : ជួបគាត់ ?

ឆាយវី : បាទ ! មកជួបគាត់

អ៊ាង : ប៉ុន្តែមានភ័យទេ ?

ឆាយវី : ភ័យបងភ័យ

អ៊ាង : ភ័យខ្លាចថាមានទោសទេ ?

ឆាយវី : បាទ ! ភ័យខ្លាចគាត់មានទោសមានគំនុំលើខ្ញុំ ព្រោះចិត្តមួយៗ ចង់សំលាប់គាត់ ប៉ុន្តែ ខ្ញុំមិនដឹងរឿងទេប៉ុន្តែគ្រាន់ថាបោកគ្រាប់បែកប្រៀបធៀបដូចសំលាប់គាត់អញ្ចឹង បាទ! ប៉ុន្តែពេលខ្ញុំចូលខ្ញុំភ័យខ្លាច ប៉ុន្តែពេលខ្ញុំចេញមកវិញឬមួយបំរើនយោបាយណាមួយ ខ្ញុំអត់ដឹងទេ ហើយដល់ពេលខ្ញុំមកជួបគាត់ជួបពួកបង ជួបបងលើកទីមួយមិនអញ្ចឹង ? នៅពេលបងនិយាយសំណេះសំណាលទៅដូចជាមិនអីដូចជាបានធូរចិត្ត ដូច្នេះ ខ្ញុំហាក់ដូចជាលែងភ័យព្រួយហើយ ក៏ត្រជាក់ចិត្ត

អ៊ាង : ប៉ុន្តែចូលភ្នំពេញហ្នឹង តើការជិះឡានចូលភ្នំពេញហ្នឹងមានអារម្មណ៍ ?

ឆាយវី : មានអារម្មណ៍ខ្លះដែរ មានអារម្មណ៍ខ្លាចថា មានគេស្គាល់ ប៉ុន្តែនៅក្នុងខ្លួនរបស់ខ្ញុំនេះ កុំថាឡើយគេស្គាល់ សូម្បីប្រពន្ធខ្ញុំក៏អត់ដឹងដែរ ក្នុងចំណោមអង្គភាពខ្ញុំក៏គេមិនដឹងថា ខ្ញុំធ្វើការនេះដែរ គឺដឹងតែលោកធឿននេះទេនិងខ្ញុំទេ ដែលដឹងអីចឹង ខ្ញុំអាចការពារសុវត្ថិភាពខ្ញុំបានតែខ្ញុំក៏មិនទាន់ទុកចិត្តច្បាស់ខ្លួនឯងដែរ

អ៊ាង : ហើយធឿនហ្នឹង ជឿទេថា ពេលជួបឆាយវីនឹងនិយាយអោយឆាយវីមកជួបនឹងលោក សម រង្ស៊ី បានមែន ?

ធឿន : បាទ !

អ៊ាង : ជឿអញ្ចឹងតែម្តង

ធឿន : បាទ ! ជឿអញ្ចឹងតែម្តង បាទ ! ព្រោះខ្ញុំប្រាកដ ប្រាកដ បើអត់លែងខ្លាចងាប់ហើយ

អ៊ាង : ហើយធឿនឯង ពេលដែលជួបឆាយវីហ្នឹង និយាយប្រាប់ឆាយវីថាម៉េចខ្លះ ?

ធឿន : ខ្ញុំនិយាយប្រាប់ថា អារឿងដែលឆាយវីឯងបានធ្វើហ្នឹង ឥឡូវអញ្ចេះ អោយយើងរត់ទៅណេះ ពីណេះទៅណោះ អត់ផ្លូវដើរអញ្ចឹងទៅ ឥឡូវចូលខ្លួនទៅសារភាពកំហុស និងប្រាប់ទៅឯកឧត្តម សម រង្ស៊ីទៅ គាត់មិនយកទោសពៃរ៍អីទេដើម្បីអោយគាត់យករឿងហ្នឹងទៅឆ្លើយបំភ្លឺជាមួយថ្នាក់លើៗទៀត កុំអោយនៅជាប់ពាក់ពិន ។ ដំបូង ពេលទៅនិយាយខ្ញុំអត់ព្រមមកទេ ដល់ចេះតែនិយាយបញ្ចុះបញ្ចូលគេទៅ ប្រាប់តាមហ្នឹងថា បើមិត្រភក្តិបើឯងយកអញទៅសំលាប់យកទៅ ងាប់ទៅ ក៏លែងស្តាយដែរ តែចងកម្មពៀរឯងរហូត ខ្ញុំថា មិត្រភក្តិដើរជាមួយគ្នារាប់ឆ្នាំហើយ នៅមិនស្គាល់ចិត្តគ្នាចេះតែនិយាយទៅ បានសុខចិត្តទៅតាមហ្នឹងណា អាលើកមុនហ្នឹងគ្រាន់តែយកទៅ ដល់គីឡូម៉ែត្រលេខ ៧ និង គ្រាន់តែដាក់ឡានចុះ ហើយប្រាប់បងឯងថា មកហើយហ្នឹង ភ័យខ្ញុំបាត់បានតាមមួយសារទៀតហ្នឹង

អ៊ាង : ឆាយវីឯងអង្គរក្ស ហ៊ុន សែន ក្រៅពីធឿន មានស្គាល់អ្នកណាផ្សេងទៀតដែរឬទេ ? អង្គរក្ស ហ៊ុន សែន ?

ឆាយវី : ខ្ញុំស្គាល់ ខ្ញុំស្គាល់ ម្នាក់ពីរនាក់អ្នកដំត្រយោង

អ៊ាង : ប៉ុន្តែអ្នកផ្សេងទៀត ?

ឆាយវី : អត់មានស្គាល់ទេ

អ៊ាង : អត់មានស្គាល់ទេ ហើយ ហ៊ីង ប៊ុនហៀងក៏ស្គាល់អត់ច្បាស់ ?

ឆាយវី : អត់ច្បាស់ទេ បើទោះជាឃើញគាត់

អ៊ាង : តើរូបរាងគាត់យ៉ាងដូចម្តេច ពេលជួបគាត់ហ្នឹង?

ឆាយវី : ជួបហ្នឹងមិនមែនជួបជាមួយបងអីចឹងៗទេ មិនយូរទេ ជួបប្រហែលជាប្រាំនាទីអីទេ ហើយក៏ បើលោកនេះប្រាប់ខ្ញុំ ថា ហ៊ីង ប៊ុនហៀង ក៏ខ្ញុំអាចចំណាំមុខដែរ ហើយបើខ្ញុំសំឡឹងមើលមុខគាត់ ឬ គោរពគាត់ តែវាមិនទាន់ប្រាប់ខ្ញុំហើយក៏មិនសូវចាប់ភ្លឹកឬមួយអ្នកនោះកូនទាហានគេ ឬមួយជាស្ពៃគេ ខ្ញុំក៏មិនដឹង មិនសូវចាប់ភ្លឹក បើសិនខ្ញុំស្គាល់គាត់ថា ជាហ៊ីង ប៊ុនហៀង ខ្ញុំក៏ចាប់ភ្លឹកដែរ...

អ៊ាង : ពេលនោះបានជិះឡានមកជាមួយគ្នាទៀត ?

ឆាយវី : បាទ ! ជិះឡានមកជាមួយគ្នា... ខ្ញុំជិះពីក្រោយគាត់

អ៊ាង : ឆាយវីឯងអត់ចាប់ភ្លឹក ?

ឆាយវី : អត់ចាប់ភ្លឹក ទាល់តែខ្ញុំចុះពីលើឡាន បានប្រាប់ថាឯងអត់ស្គាល់ទេហ្នឹង ហ៊ីង ប៊ុនហៀងប្រធានអង្គរក្ស បានខ្ញុំចាប់ភ្លឹកថា អូ !...

អ៊ាង : ប៉ុន្តែធឿនឯងស្គាល់ច្បាស់តែម្តង ហ៊ីង ប៊ុនហៀងហ្នឹង?

ធឿន : ...

អ៊ាង : ហើយគាត់ស្គាល់ធឿនឯងច្បាស់តែម្តង ?

ធឿន : បាទ !

អ៊ាង : ឥឡូវ តើធឿនឯងហ៊ានទេបើខ្ញុំនាំធឿនឯងទៅជួប ហ៊ីង ប៊ុនហៀង ?
ធឿន : ហ៊ានបង !
អ៊ាង : ហ៊ានទៅជួបគាត់ដែរ ?
ធឿន : បាទ! អោយតែបងឯងការពារសុវត្ថិភាពខ្ញុំ ខ្ញុំហ៊ានទៅ...
អ៊ាង : ហ៊ានទៅជួបតែម្តង ! អត់ខ្លាចគេចាប់ទេ ?
ធឿន : អ្ហេ ! អាហ្នឹងលើបងឯងជាអ្នកកាពារសុវត្ថិភាពរបស់ខ្ញុំ...
អ៊ាង : គាត់បាញ់ ! បងប្អូនទាំងអស់គ្នាកុំបារម្ភ ឥឡូវក្នុងចិត្តមានខ្លាចថា អ្នកដែលដឹងរឿងៗ ខ្ញុំដឹងរឿងអីហ្នឹង នឹងនាំឆាយវីឯងទៅអោយប៉ូលិស ទៅអោយអី ភ័យខ្លាចអញ្ចឹងទេ ?
ឆាយវី : ក្នុងចិត្តខ្ញុំបារម្ភត្រង់នេះទេ ត្រង់ថា បើកាលណាការងារនេះមិនទាន់សំរេច ហើយយកឈ្មោះខ្ញុំទៅផ្សព្វផ្សាយ គឺខ្ញុំពិបាកត្រង់ហ្នឹង ខ្ញុំសំណូមពរថា បើការនេះមិនទាន់ធ្វើកើត ឬមួយអ្វីមួយយើងកុំអាលធ្វើខុសណាបងណា ការហ្នឹងខ្ញុំពិបាក
អ៊ាង : ប៉ុន្តែប្រសិនបើគេ មានគេ ញុះញង់... អញ្ចឹងយល់យ៉ាងណាដែរ ?
ឆាយវី : ក្នុងពេលខះណៈនេះ បើកាលណាមិនផ្សព្វផ្សាយមិនអីទេ ខ្ញុំអាចការពារសុវត្ថិភាពខ្ញុំបានទេ
អ៊ាង : ប៉ុន្តែគេចង់ផ្សព្វផ្សាយ ប៉ុន្តែគេអោយមនុស្សទៅផុតអញ្ចឹងដែរ?
ឆាយវី : ខ្ញុំដូចមិនចង់ចេញមកដែរទេ
អ៊ាង : មូលហេតុអី ?
ឆាយវី : គ្មានមូលហេតុអី គ្រាន់តែមិនចង់ចេញ
អ៊ាង : ធម្មតាម៉េចបានមិនចង់ចេញ គេផ្តត់ផ្តង់ អីធម្មតាដូចថាមកនៅអីចឹងណា ហើយដល់ពេលគេចង់ធ្វើការអ្វីមួយ តើអាចបានទេ ?
ឆាយវី : អាហ្នឹង សុំមួយរយៈសិន ទាល់នាំប្រពន្ធនាំកូនមក តែចាំវិភាគជាមួយបងប្អូនសិន
អ៊ាង : បើចង់វិភាគ ទាល់តែប្រពន្ធសួរដេញដោល ប្រពន្ធសួរថាចុះម៉េចឯងក៏ ឆាយវីឯងថា ប្រពន្ធកូនអត់ដឹងរឿងទេ ?
ឆាយវី : បាទ !
អ៊ាង : បើយើងមិនមានការអីយើងមកនៅស្រុកថៃចាំគេជួយមើលការខុសត្រូវយើង...
ធឿន : ត្រង់នេះពិបាកនិយាយជាមួយប្រពន្ធថាឯង ទៅនៅឯនោះទៅ នៅនេះពិបាករកស៊ី ទៅឯនោះ គេមានលុយចិញ្ចឹម គេមានបាយហូបមានអីអញ្ចឹងទៅ អោយលក់ដីលក់អីអញ្ចឹងមក ហើយមកនេះអាហ្នឹងទាល់តែគេផ្ចិតមេដៃគ្នាជុំគ្នាសិន ទើបហ៊ានសំរេច
អ៊ាង : ហើយ ជួនកាលអាច អាចបង... ជួនកាលគេអាចជួយប្រពន្ធកូនអោយ...គេសុខចិត្តជួយ ជាក់ស្តែងគ្រាន់ថាឲ្យឆាយវីឯងមកតំបន់មួយមានសុវត្ថិភាព មានសុវត្ថិភាព ហើយដើម្បីអោយគេធ្វើការ ព្រោះបើគេប្រកាសជាចំហ ដើម្បីធ្វើការស៊ើបអង្កេតអាហ្នឹងឈានដល់ករណីហ្នឹងណា
ធឿន : អញ្ចឹង... បងអាចនិយាយថា បើសិនជាខ្ញុំអ្នកធ្វើវិញខ្ញុំដាច់ចិត្តជាងនោះភ្លាម តែនៅទាក់ទាមរឿងកូនប្រពន្ធ ខ្ញុំដាច់ភឹងៗហើយ ។
អ៊ាង : អូ ! ភ្លេចសួរ ម៉ូតូហ្នឹងទិញម៉ាកអី ?
ធឿន : ហ៊ីុអ៊ែរ
អ៊ាង : ហ៊ីុអ៊ែរ ទិញនៅភ្នំពេញ ?
ធឿន : ទិញនៅភ្នំពេញ
អ៊ាង : ទិញនៅម៉ុំណា ?
ធឿន : នៅអូរឫស្សី
អ៊ាង : អូរឫស្សី ដល់លក់ៗនៅកំពង់ចាម ?
ធឿន : កំពង់ចាម
អ៊ាង : លក់ខាតប៉ុន្មាន ?
ធឿន : ទិញមកប្រាំបីរយ លក់បានប្រាំពីររយចិតប្រាំពីររយប៉ែតដែរ
អ៊ាង : ជិះបានប៉ុន្មានថ្ងៃ ?
ធឿន : បើតាមគិតទៅ មិនដល់មួយអាទិត្យទេ អត់ដល់មួយអាទិត្យទេ បើតាមគិតទៅ បានប្រហែលប្រាំថ្ងៃទៅប្រាំមួយថ្ងៃ
អ៊ាង : ហើយនៅពេលដែលគាត់ហុចលុយអោយ នៅពេលឡានឈប់ ឬ មុនចុះឡាន ?
ធឿន : អោយក្នុងឡាន
អ៊ាង : ក្នុងឡានពេលគាត់ឈប់ អោយ ឬក៏...
ធឿន : ក្នុងឡាន ពេលបើក ពេលហុចលុយហ្នឹងក៏មិនមើលមុខខ្ញុំផង ។ អោយធឿនហុចអោយ...
អ៊ាង : រួចហើយបានគាត់ថា បើបានសំរេច
ធឿន : បាន បានលុយ
អ៊ាង : ឥឡូវអោយមួយពាន់ចាយសិន
ធឿន : អោយមួយពាន់ចាយសិន
សួម៉្វា : ហើយគាត់អត់ប្រាប់ថាពេលណាអោយទៅយកលុយប្រាំបួនពាន់ដែលនៅសល់?
ឆាយវី : ពេលបែកហើយ អោយទៅយក
សួម៉្វា : អញ្ចឹង ! បើបែកហើយអោយទៅតាមភ្លាមៗ គាត់ប្រាប់ថាអោយទៅវត្តបុទុមតែម្តង
ឆាយវី : បាទ ! អត់ទេផ្ទះ...

សូម្វ៉ា : អីចឹងបានន័យថា គ្រាប់បែកហើយភ្លាមៗហ្នឹង ចូលយកលុយ

ឆាយវី : អត់មានទេ ! ហើយចូលទៅហ្នឹងហើយ តែមិនមែនចូលទៅយកលុយទេ ចូលទៅរកគេចខ្លួនទេ ប៉ុន្តែដោយមើលក្នុងទាហានពួកអាសំណាញ់ប៉ុន្មាននាក់ហ្នឹង ខ្ញុំមើលសភាពវា មិនស្រួល ហើយបើស្រួល ខ្ញុំចូលទៅមុនគេ គ្មានអ្នកណាគេនៅខាងក្នុងដែរ មានសុទ្ធតែទាហានទាំងអស់ ហើយក៏មិនដឹងជាអ្នកណាៗទេខ្ញុំក៏ប្រឹងគេចខ្លួន

សូម្វ៉ា : ហើយចុះលោកឯងពេលហ្នឹង ម៉េចមិននឹកឃើញថា រកហ៊ីង ប៊ុនហៀង ទៅទារគាត់ ព្រោះគាត់ប្រាប់ថាលោកគ្រាប់បែកផ្ទុះហើយទៅរកគាត់វិញ ?

ឆាយវី : អីចេះអត់មានទេ ! បង ! ព្រោះខ្ញុំដឹងខ្លួនខ្ញុំដែរបង ពេលធ្វើហើយ បានខ្ញុំដឹងក្នុងចិត្តថា ខ្ញុំពេលនេះ ខ្ញុំដឹងថាចាញ់បោកចាញ់ប្រាជ្ញាគេហើយ ព្រោះពេលខ្ញុំធ្វើការនេះហើយគួរតែគេចាំទទួលខ្ញុំ ឬមួយ អាហ្នឹងវាបែក ពេលធ្វើហើយបែរជាគ្មានមនុស្សនៅក្បែរសុទ្ធតែគ្នាគេទាំងអស់ ទាហាន ឬមួយទាហានម៉េចៗក៏ខ្ញុំអត់ដឹងដែរ ព្រោះថា មិនទំនង គេចង់ស៊ី ឬគេចង់ធ្វើអី ខ្ញុំមិនបានសួរនាំគេ គេក៏មិនបានសួរនាំខ្ញុំដែរ ខ្ញុំគេចខ្លួនទៅភ្លាម

អ៊ាង : ពេលដែលលោកហើយមានមើលទៅក្រោយទេ ?

ឆាយវី : ខ្ញុំ អើ មិនមែនថាមិនមើលទេ មើលខ្លះដែរ ប៉ុន្តែវាព្រិលវារាងហ្នឹង តែមានគេតាមពីក្រោយ តែមិនដឹងជានរណាទេ

អ៊ាង : ពេលរត់ហ្នឹង ?

ឆាយវី : ពេលរត់ តែមិនដឹងជាអ្នកណាទេ អត់ដឹង

សូម្វ៉ា : ពេលបោះហើយ...

ឆាយវី : បាទ ! បោះហើយខ្ញុំរត់ ហើយមានគេតាម តែមិនដឹងជានរណា។

អ៊ាង : ហើយទាហាន ដែលគេយាមនៅហ្នឹង ក៏គេព្រលែង ?

ឆាយវី : គេមិនព្រលែងទេ ថាគេព្រលែងថាគេចុះ គេមិនរវល់នឹងខ្ញុំទេណា គេកំពុងតែស្អីណាការពារខ្លួនស្អីណា ពេលនោះគេរកកន្លែងណានៅទេ ប៉ុន្តែគេមិនបានឃាត់ខ្ញុំទេ ហើយគេក៏មិនបានហៅសួរនាំខ្ញុំដែរ ពេលកំពុងតែជ្រួលច្របល់ ខ្ញុំទៅគេត្រៀមខ្លួនគេ គេមិនហាមឃាត់ខ្ញុំជាជនស៊ីវិល បើឃើញទាហានទំនងអីចេះអីចុះដែរ ខ្ញុំក៏...

ធឿន : ព្រោះកន្លែងនោះ សុទ្ធតែជាកំលាំងអង្គរក្ស...

ឆាយវី : ព្រោះគេថា ខ្ញុំពួកក្រុមបាតុកម្មគេក៏អត់ដឹងរឿងគេខ្ញុំអត់ដឹង។

សូម្វ៉ា : ហើយអ្នកដែលបោះសញ្ញា បោះសញ្ញានោះ

អ៊ាង : បោះក្រដាស...

សូម្វ៉ា : បោះក្រដាស ឬ បោះកន្ទុយបារី...?

ឆាយវី : អូ អា ! បោះជាសញ្ញាហ្នឹងណា ! អត់ទេ មានក្រដាសមួយស ដូចជាក្រដាសកាសែត វាមូរអីអញ្ចឹងៗបោះចំកែងបណ្ដោយ បោះចំកន្លែងដូចជា ថាបងនៅត្រង់នេះចំងាយហ្នឹង...

*(កំពុងគូរគំនូសតាង)*

សូម្វ៉ា : គូរផ្លូវសភា នេះវាំង នេះផ្លូវជាប់វាំង នេះរដ្ឋសភា

អ៊ាង : នេះវាំង រាជវាំង នេះរដ្ឋសភា ផ្លូវមុខវត្តបុទុមកន្លែងបាតុកម្មនេះ អ្នកដែលបោះក្រដាសបោះកន្លែងណា ?

ឆាយវី : បោះនៅត្រង់នេះ

អ៊ាង : បោះខាងនេះវិញ

ឆាយវី : បាទ ! នៅខាងចុង

អ៊ាង : បានន័យថា ឆាយវីឯង បើពេលចុះចុះនៅត្រង់ណា ?

ឆាយវី : ខ្ញុំចុះនៅក្រោមដើមស្ពឺ ដើមមៀន...

អ៊ាង : ហើយ អ្នកដែលបោះក្រដាសបោះនៅកន្លែងណា?

ឆាយវី : បោះក្រដាស បោះទីបីទីពីរម្ដុំចំមុខបណ្ដោយ អាមុខគេហ្នឹង

អ៊ាង : ក្រដាស ក្រដាស

ឆាយវី : ក្រដាសដែលគេបោះស៊ីញ៉ូមកហ្នឹង ? គេបោះមិនចំជ្រុងហ្នឹងទេ គេបោះរាងចុងកណ្ដាលនិងចុង

អ៊ាង : នេះបាតុកម្ម

សូម្វ៉ា : ខាងនេះសភា

ឆាយវី : សភា

សូម្វ៉ា : ឈប់ៗ ឆាយវីឯង លោកវីឯងឈរនៅត្រង់ណា...?

ឆាយវី : ខ្ញុំឈរនេះ ឈរកន្លែងដើមមៀនហ្នឹង ហើយអាផ្លូវកែង

សូម្វ៉ា : ខ្ញុំចង់ដឹងថាឈរនៅកន្លែងណា ពេលបោះស៊ីញ៉ូហ្នឹង ?

ឆាយវី : ពេលបោះស៊ីញ៉ូ ខ្ញុំនៅពីក្រោមដើមអំពិលនេះ ខ្ញុំទៅដល់ក្រោមដើមអំពិល បោះពីក្រោយខ្ញុំឆ្លងផ្លូវ

អ៊ាង : ប៉ុន្តែអ្នកដែលបោះក្រដាស មូរក្រដាសសញ្ញាហ្នឹង គេឈប់នៅណា ?

ឆាយវី : បើបញ្ជាក់បន្តិច ខ្ញុំមិនដឹងដែរ ខ្ញុំនៅពីក្រោយគ្រាន់តែឮបោះក្រដាស

*(អ្នកសំភាសន៍កំពុងទទួលទូរស័ព្ទ)*

សូម្វ៉ា : ឈប់ៗ ឡើងជិះម៉ូតូនៅត្រង់កន្លែងណា ?

ឆាយវី : ឡើងជិះកន្លែងខាងក្រោយ វត្តស្ពឺគេនេះហើយ បានគេបើកផ្លូវនោះមក ចេញអាខាងវាលមេរុ

សូម្វ៉ា : អូ ! វាងអញ្ចឹង ឡើងម៉ូតូនៅកន្លែងមុខវត្តបទុម ក្នុងវត្តបទុម...

ឆាយរី : នៅក្នុង នៅខាងក្រោយ...

សូម្ភ៉ា : អញ្ចឹង មិនមែនមានន័យថា មិនមែននៅក្នុងវត្តបទុមទេ...

អ៊ាង : នៅក្នុងឬកហ្នឹងហើយ ប៉ុន្តែឬកវាធំ

សូម្ភ៉ា : រួចទៅ វាងទៅដល់សារមន្ទីរ

ឆាយរី : ទៅវាលមេរុ ហើយបានជិះកាត់មុខវាំងមកវិញ...

សូម្ភ៉ា : ហើយម៉ូតូឈប់នៅត្រង់កន្លែងណា ?

ឆាយរី : ពេលមក ខ្ញុំឈប់នៅ...

សូម្ភ៉ា : ក្រោមដើមមៀន រួចមេចទៅ ពេលម៉ូតូឈប់ហ្នឹងលោកឯងឈប់ត្រង់ហ្នឹង ឬក៏ទៅណាទៀត ?

ឆាយរី : ខ្ញុំចុះនៅត្រង់នេះ ដល់ពេលចុះនៅត្រង់នេះប្រហែលប្រាំនាទីប្រាំមួយនាទីហ្នឹង គេមក ប៉ុន្តែបាតុកម្មគេនៅនេះហើយ ខ្ញុំក៏ឆ្លងផ្លូវទៅនៅក្រោមដើមអំពិលនេះវិញ

សូម្ភ៉ា : អូយេ! ពេលដែលម៉ូតូលោកឯងមកដល់ហ្នឹង តើពួកបាតុករគេមកដល់ហើយឬនៅ ?

ឆាយរី : គេមកដល់ហើយ

សូម្ភ៉ា : គេមកដល់មុនយូរហើយ ?

ឆាយរី : បាទ !

សូម្ភ៉ា : ចុះពេលលោកឯង ពេលដែលម៉ូតូឈប់ហ្នឹងប្រហែលខ្ទង់ម៉ោងប៉ុន្មាន ? ចាំទេ ?

ឆាយរី : អត់បានចាំផង...

សូម្ភ៉ា : មានទាំងអស់គ្នានៅហ្នឹងហើយ ?

ឆាយរី : បាទ!ហើយដល់ពេលខ្ញុំមក ខ្ញុំមកតែឯងទេ ខ្ញុំមិនដឹងគេមកពីស្មើណាអីស្មើណា ខ្ញុំអត់ដឹងទេ ប៉ុន្តែពេលខ្ញុំជិះមក ខ្ញុំជិះតែឯងទេ មិនដឹងជាអ្នកណាទេ ប៉ុន្តែមិនទាន់ដឹងគេមកមុនខ្ញុំ ឬស្អី ខ្ញុំមិនដឹងទេ ម៉ូតូឈប់ហ្នឹង ខ្ញុំមិនទាន់ដឹងថាឈប់ត្រង់ណាៗទេ ប៉ុន្តែអ្នកជិះម៉ូតូមួយមុខ គេអោយបោះក្រដាស ឬមួយស្អីត្រង់ហ្នឹង ខ្ញុំឈប់នៅត្រង់ហ្នឹង ប៉ុន្តែមិនមែនខ្ញុំអ្នកអោយឈប់ទេណា

សូម្ភ៉ា : អញ្ចឹង! មានម៉ូតូមួយមុខបោះក្រដាស

ឆាយរី : បាទ ! ហើយខ្ញុំឈប់នៅត្រង់នេះ

អ៊ាង : ម៉ូតូឆាយរីឯងឈប់ត្រង់ហ្នឹង ?

ឆាយរី : បាទ !

សូម្ភ៉ា : បោះក្រដាស ក្រដាសយ៉ាងម៉េចទៅក្រដាសចូរមូរអញ្ចឹងទៅ ?

ឆាយរី : បាទ ! មូរដូចក្រដាសកាសែត

សូម្ភ៉ា : អស់ប៉ុណ្ណឹងទៅ អាម៉ូតូហ្នឹងវាឈប់ទៅ ហើយគេប្រាប់ឆាយរីឯងចុះទៅ ?

ឆាយរី : បាទ! គេថាបងឯងចុះទៅខ្ញុំក៏ចុះត្រង់ហ្នឹងទៅ ខ្ញុំឈរមើលចុះមើលឡើងៗអញ្ចឹងទៅ ក៏ឃើញ ក្រែងលោមានគ្នាច្រើនស្មានខ្ញុំតែឯង ខ្ញុំក៏ដើរឆ្លងទៅរកកន្លែង ក្រោមដើមអំពិលនេះ

សូម្ភ៉ា : អ្នកណាប្រាប់អោយទៅក្រោមដើមអំពិលហ្នឹង ?

ឆាយរី : ខ្ញុំទៅខ្លួនឯងទេ

សូម្ភ៉ា : លោករីឯងអត់មានទទួលបញ្ជាអីពីអ្នកណាទាំងអស់ ?

ឆាយរី : អត់មានទទួលអីទាំងអស់

សូម្ភ៉ា : អត់មានប្រាប់ថា អោយឈរត្រង់ណាអីត្រង់ណីទេ ?

ឆាយរី : បាទ ! អត់មានទេ...

សូម្ភ៉ា : រួចហើយ ដើរទៅ ឆ្លងក្រោមដើមអំបិលនេះ

ឆាយរី : បាទ !

សូម្ភ៉ា : រួចទៅ !

ឆាយរី : រួចទៅឃើញអាប្រេស៊ីល ប្រេស៊ីលមួយហ្នឹង ដែលគប់ប្រេស៊ីលហ្នឹងដែលគប់លើកទី១ នៅអែបត្រង់សភាគប់ទៅណាទៅណាមិនដឹង កំពុងតែយាអញ្ចេះ វាងាកទៅខ្ញុំក៏ចាប់ផ្តើមឆ្លងមកខាងសួនច្បារនេះវិញ

សូម្ភ៉ា : អញ្ចឹងឃើញប្រេស៊ីលគប់ពីនេះមក ?

ឆាយរី : បាទ ! អែបសភា...

សូម្ភ៉ា : ជិតសភា ក្បែររបងសភា ឃើញប្រេស៊ីលគប់គ្រាប់បែកហើយ

ឆាយរី : បាទ !

សូម្ភ៉ា : រួចពីប្រេស៊ីលគប់គ្រប់បែកទៅ លោកឯងដើរពីនេះទៅកន្លែងណានេះ

ឆាយរី : ខ្ញុំដើរ ក្នុងពេលនោះ ខ្ញុំបែរ... សួននៅខាងណោះ

សូម្ភ៉ា : ចា

អ៊ាង : ក្នុងសួនហ្នឹង

ឆាយរី : បាទ ! នៅកន្លែងហ្នឹង ខ្ញុំគប់ហើយ ខ្ញុំក៏គេចទៅ

សូម្ភ៉ា : អូ ! អញ្ចឹង ប្រេស៊ីលគប់ហើយ បានលោកឯងគប់

ឆាយរី : គ្រាប់ទី៤ ណោះ...

សូម្ភ៉ា : ចុះពេលណាដែលឃើញសញ្ញា ដែលគេបោះក្រដាសហ្នឹង ក្រែងត្រូវគប់នៅពេលណាគេបោះសញ្ញាទេឬ ?

ឆាយរី : បាទ ! ដល់ពេលគេបោះក្រដាសហើយ ប្រហែលជាប្រាំនាទី ខ្ញុំរត់មកខាងនេះ ប៉ុន្តែគ្រាន់តែមកដល់កន្លែងអានេះលេងភ្លឹប ខ្ញុំក៏លេងទៅជាមួយវាហើយតែម្តង ។

សូម្ភ៉ា : អូ! សញ្ញាក្រដាសហ្នឹង មិនសំរាប់អោយគប់ទេ អោយចុះពីម៉ូតូ ?

ឆាយរី : អត់ទេ ! បោះសញ្ញាត្រង់ណាគឺអោយគប់ត្រង់នោះ

សូម្វ៉ា ៖ ក៏ប៉ុន្តែ...

ឆាយវី ៖ ខ្ញុំចុះពីលើម៉ូតូភ្លឹប ខ្ញុំចុះគឹប ម៉ូតូវាលឿង ខ្ញុំឈរប្រហែល ១៥នាទី មិនទាន់ឆ្លងកាត់នេះ ព្រោះក្នុងពេលបាតុកម្មនោះមិនទាន់ជុំឬមិនទាន់ស្អីខ្ញុំមិនដឹងទេណា បានប្រហែលជាប៉ុន្មានទៀត បានគេលេង អាប្រេស៊ីល វាលេងគប់ទៅបានខ្ញុំគប់ ឆ្លងមក ខាងនេះ...

សូម្វ៉ា ៖ អញ្ចឹង បើតាមបញ្ហា គេអោយយើងហ្នឹងគឺចាំអោយតែមានអ្នកណាមួយគប់គ្រាប់បែកហើយ បានយើងបន្តទៀត ?

ឆាយវី ៖ បាទ ! មិនមែន គេមិនអោយបន្តទេ គេសុំអោយលីស្លូវតែមួយផង គេចង់អោយលីស្លូវតែមួយផងតែធ្វើម៉េចឲ្យរួចខ្លួនផងដែរ ។

អ៊ាង ៖ បើអញ្ចឹង ...

ឆាយវី ៖ អោយគប់ត្រង់ណា អីត្រង់ណា គេមិនដឹងគេប្រាប់ឬអត់ទេ... ប៉ុន្តែរឿងខ្ញុំ គាត់អត់មានប្រាប់ទេត្រង់គប់ត្រង់ណាត្រង់ណាមិនដឹងទេ

អ៊ាង ៖ អោយតែឮស្លូវផ្ទុះ...អោយផ្ទុះនឹងគេដែរទៅ ?

ឆាយវី ៖ បាទ ! អោយផ្ទុះនឹងគេដែរទៅ

សូម្វ៉ា ៖ អញ្ចឹង ! សញ្ញាក្រដាស់ហ្នឹង គឺមិនមែនសញ្ញាអោយឈប់ម៉ូតូទេ រួចពីហ្នឹង អត់មានសញ្ញាអ្វីដីទៃទៀតទេ ?

ឆាយវី ៖ អត់ទេ ! សញ្ញានេះ សញ្ញាក្រដាស និងសញ្ញាម៉ូតូហ្នឹង ក្រដាសដែលខ្ញុំឈប់ហ្នឹង មិនមែន មិនមែនបោះក្រដាសអោយខ្ញុំឈប់ម៉ូតូទេណា ពេលម៉ូតូខ្ញុំឈប់ហ្នឹងអាអ្នកម៉ូតូឌុបដែលពាក់មួកហ្នឹង គេបោះសញ្ញាក្រដាស់ហ្នឹងអោយគប់ បានអានេះវាគប់ បានខ្ញុំក៏ឆ្លងកាត់ទៅហ្នឹង ម៉ូតូមិនទាន់មកទេ

អ៊ាង ៖ ឈប់ៗ ខ្ញុំចង់អោយច្បាស់ បញ្ហាហ្នឹង ។ ឆាយវីឯងឈប់ម៉ូតូ ឆ្លងផ្លូវហើយឬនៅ ពេលគេបោះស៊ីញ៉ូក្រដាសហ្នឹង ?

ឆាយវី ៖ នៅទេ ! ខ្ញុំឈរទេ មិនទាន់ឆ្លងទេ ខ្ញុំឆ្លងមកដល់នេះហើយ បានគេបោះក្រដាស បានអានេះវាគប់ទៅនេះ មិនមែនបោះក្រដាសនេះ ឈប់ទេ មិនមែនទេ

សូម្វ៉ា ៖ អូយេ ! ខ្ញុំយល់ៗ លោកឆាយវីឯងថា អាម៉ូតូនេះជិះមុខហ្នឹង វាបោះក្រដាសទៅ បានម៉ូតូយើងនេះឈប់

ឆាយវី ៖ មិនមែនទេៗ ម៉ូតូដែលខ្ញុំឈប់នេះ ម៉ូតូក្រោយ ម៉ូតូពាក់មួកស៊ីញ៉ូក្រដាសដែលគប់ហ្នឹង មិនមែនម៉ូតូបោះ ក្រដាសនេះគប់មិនងាប់ខ្ញុំត្រង់ហ្នឹងទេ... ប៉ុន្តែមានបោះក្រដាសមួយ ត្រង់កន្លែងនេះ

អ៊ាង ៖ ឃើញគេបោះក្រដាស ?

ឆាយវី ៖ ឃើញបោះក្រដាស

សូម្វ៉ា ៖ ហើយៗ អ្នកបោះក្រដាសហ្នឹងជិះម៉ូតូ ?

ឆាយវី ៖ ជិះម៉ូតូ ! ម៉ូតូគេទៅមុខហើយ មិនដឹងជាអ្នកណាជាអ្នកណាទេ សុទ្ធតែពួកហ្នឹងទាំងអស់ ប៉ុន្តែខ្ញុំស្គាល់តែអាប្រេស៊ីលហ្នឹងមួយ មិនស្គាល់គេច្បាស់ទេ គ្រាន់តែចំណាំ ចាប់ភ្លឹកមនុស្សហ្នឹង

សូម្វ៉ា ៖ រួចទៅ ! ម៉ូតូហ្នឹងបោះក្រដាសហើយប្រេស៊ីលគប់ភ្លាម

ឆាយវី ៖ បាទ ! ប្រេស៊ីលគប់

សូម្វ៉ា ៖ ដល់អញ្ចឹង ! លោកឯង គប់ទៅ ?

ឆាយវី ៖ នេះ គឺថា គប់តៗគ្នា រំលងកាត់សួនហ្នឹង

សូម្វ៉ា ៖ ពីក្រោមដើមអំពិលហ្នឹង ?

ឆាយវី ៖ បាទ ! ពីក្រោមដើមអំពិលហ្នឹងទៅ

សូម្វ៉ា ៖ ចុះ ! អញ្ចឹង មានន័យថា គេបានប្រាប់លោកវីឯងដឹងអញ្ចឹងថា អាស៊ីញ៉ូហ្នឹង គឺក្រដាសហ្នឹង ?

ឆាយវី ៖ គឺក្រដាសហ្នឹង គឺថា បើឃើញទំលាក់ក្រដាស់ត្រង់ណា គឺត្រូវផ្ទុះ នៅកន្លែងនោះ

សូម្វ៉ា ៖ អញ្ចឹង ក្រដាសនោះ បង្ហាញគោលដៅ ?

ឆាយវី ៖ បាទ ! បង្ហាញគោលដៅ ពេលចេញ

សូម្វ៉ា ៖ បង្ហាញពេលវេលាផង បង្ហាញគោលដៅផង ?

ឆាយវី ៖ បង្ហាញពេលវេលា ឬគោលដៅ គេបោះកន្លែងណា គឺយើងអត់មានពេលវេលាទេ បោះត្រូវន្លែងណាត្រូវគប់ត្រង់កន្លែងនោះ

សូម្វ៉ា ៖ ត្រូវហើយៗ ហើយក្រដាសនោះ វាត្រូវធ្លាក់ប្រហែលផ្ទុះនៅកន្លែងណា ?

ឆាយវី ៖ ... ចំកណ្តាលថ្នល់ ចំចំហៀងថ្នល់រមៀលថ្នល់បន្តិចខ្ញុំឆ្លងមកដល់នេះ ហើយណា ហើយបានគេមកក្រោយបានគេគប់មកនេះហើយបានខ្ញុំ បោះខាងសួនច្បារ...ឯណោះវិញ

សូម្វ៉ា ៖ អញ្ចឹងៗ លោកឯងឈប់ឈរនៅក្រោមដើមអំពិលហ្នឹងទៀតហើយពេលដែលបោះគ្រប់បែកហ្នឹង ?

ឆាយវី ៖ បាទ ! បាទ !

សូម្វ៉ា ៖ មកនៅឯណោះវិញហើយ

ឆាយវី ៖ បាទ ! អត់ទេ ទីមួយឈប់នៅត្រង់នេះ ហើយបានឆ្លងផ្លូវនេះ មកនៅក្រោមដើមអំពិលនេះ បានម៉ូតូវាមក...

សូម្វ៉ា ៖ គេបោះក្រដាសទៅ

ឆាយវី ៖ បាទ ! បោះក្រដាសទៅ ខ្ញុំស្គាល់អ្នកនោះ មិនដឹងអ្នកណាអ្នកណាទេ

សូម្វ៉ា ៖ រួចទៅ ដល់ពេលម៉ូតូហ្នឹង បោះក្រដាស់ហ្នឹងហើយនៅចំកណ្តាលថ្នល់ហ្នឹង

ឆាយវី ៖ បាទ ! បានអានៅអែបនេះ គប់

សូម្វ៉ា ៖ ចា ! រួចហើយ...

ឆាយវី ៖ គប់ហើយបានគេបន្តៗរៀងគ្នាច្រើន មិនដឹងអ្នកណាទេ បានហើយខ្ញុំគប់ផុតអាទីបួនមកខាង សួនច្បារនេះ

សូម្ម៉ារ៉ា ៖ ពេលហ្នឹងៗ ពេលគប់គ្រាប់បែកហ្នឹងតើលោកវីឯងនៅតែក្រោមដើមអំពិលដដែល ឬក៏បានដើរទៅខាងសួនច្បារហើយ ?

ឆាយវី ៖ អត់ទេ ! ខ្ញុំដើរកាត់ផ្លូវហើយ ខ្ញុំគប់បណ្តោយ ទៅបណ្តោយ

សូម្ម៉ារ៉ា ៖ អញ្ចឹងៗ ពីនេះទៅ ដើរមកនេះមក អញ្ចឹងមានន័យថា... លោកឯងឈប់ត្រង់នេះណា

ឆាយវី ៖ បាទ !

សូម្ម៉ារ៉ា៖ រួចហើយ ដើរទៅក្រោមដើមអំពិល ឃើញម៉ូតូមួយបោះក្រដាស

ឆាយវី ៖ បាទ !

សូម្ម៉ារ៉ា ៖ ឃើញប្រេស៊ីលគប់ លោកឯងដើរមកនេះ លោកឯងគប់ដែរ

ឆាយវី ៖ បាទ !

សូម្ម៉ារ៉ា ៖ អញ្ចឹង លោកឯងឈរប្រហែលខ្នងកន្លែងនេះ នៅពេលដែលឈរគប់គ្រាប់បែក

ឆាយវី ៖ ខ្ញុំគប់មកខាងសួននោះវិញ

សូម្ម៉ារ៉ា ៖ បោះអាគ្រាប់បែកទៅរកសួន អត់បោះមករក...?

ឆាយវី ៖ ទេ ! អត់មានបោះមកខាងៗ...

សូម្ម៉ារ៉ា ៖ ចុះក្រែងថា អាក្រដាសហ្នឹងជាគោលដៅ ?

ឆាយវី ៖ គោលដៅ ! ប៉ុន្តែ គ្រាន់តែឮពឹងៗហ្នឹងខ្ញុំដូចជាល្ងើ ចេះតែទៅៗហើយ សំដៅទៅខាងនោះ មិនមែនតម្រង់ទៅឯណា

សូម្ម៉ារ៉ា ៖ អញ្ចឹង ពេលដែលលោកឯងបោះហ្នឹង លោកឯងឈរនៅកន្លែងសួនច្បារ មិនមែនឈរនៅក្រោមដើមអំពិលទេណោះ ?

ឆាយវី ៖ ពេលបោះខ្ញុំនៅឈរនៅក្រោមដើមអំពិល

សូម្ម៉ារ៉ា ៖ លោកឯងឈរក្រោមដើមអំពិល ហើយបោះទៅរកសួនច្បារវិញ

ឆាយវី ៖ សួនច្បារវិញ ប៉ុន្តែគោលដៅគេថាមួយឬកហ្នឹង យើងចាំបាច់នេះធ្វើអ្វី គេថាអោយតែផ្ទុះណាហ្នឹង

សូម្ម៉ារ៉ា ៖ អញ្ចឹងមានន័យថា លោកឯងអត់បានបោះតាមបញ្ជាគេទេណា

ឆាយវី ៖ អត់តាមទេ...

អ៊ាង ៖ បញ្ជាហ្នឹង...

ឆាយវី ៖ ...គេថា អោយតែផ្ទុះ

អ៊ាង ៖ ការពិតគេបោះក្រដាសនេះទៅ បានឃើញប្រេស៊ីលបោក ចំអាចំណុចហ្នឹងទេ

សូម្ម៉ារ៉ា ៖ តែប្រេស៊ីលបោកទៅតាមរកក្រដាសគេនោះមែន...

អ៊ាង៖ ហើយគាត់ គាត់អត់ឃើញអាក្រដាស អត់ចាប់អារម្មណ៍...

សូម្ម៉ារ៉ា ៖ ប៉ុន្តែក្រែងឃើញក្រដាសធ្លាក់ដែរ ?

ឆាយវី ៖ ខ្ញុំឃើញក្រដាសហ្នឹងដែរ ប៉ុន្តែខ្ញុំឃើញក្រដាសហ្នឹងភុងៗតែម្តង ខ្ញុំក៏គេចខ្លួនខ្ញុំដែរ ដល់ពេលបោះទៅខាងសួនច្បារឯណោះ វាលមិនមែននៅខាងណេះទេ

សូម្ម៉ារ៉ា៖ បោះទៅកន្លែងសួនច្បារ រួចហើយបានលោកឯងរត់ពីនេះ ទៅអញ្ចឹង

ឆាយវី ៖ បាទ ! រត់ទៅវត្តហើយមានឃើញទាហានគេយាមមួយជួរខាងនេះ

អ៊ាង ៖ ហើយអ្នកដែលតាមឃ្លាំឆាយវីឯងមានរត់ដែរទេ ?

ឆាយវី ៖ បាត់ហើយ ពេលនោះ បាត់ហើយ បាត់ពេលបោកហើយ

អ៊ាង ៖ អរគុណ ! ឆាយវី